ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# សេចក្តីព្រាង

# ផែនការអនុវត្តការងារគណនេយ្យភាពសង្គម

# ដំណាក់កាលទី៣ (២០២៦-២០៣០)

ខែសីហា ឆ្នាំ២០២៦

# អារម្ភកថា

# មាតិកា


អារម្ភកថា ........ i

មាតិកា ........ ii

ជំពូកទី១ និដ្ឋភាពទូទៅ ........ 1

១. សេចក្តីផ្តើម ........ 1

១.១. សមិទ្ធផលសំខាន់ៗ ........ 2

១.២. មេរៀន បទពិសោធន៍ និងបញ្ហាប្រឈម ........ 7

១.៣. ដំណើរការរៀបចំ ISAF-III ........ 9

២. ចក្ខុវិស័យ គោលបំណង គោលដៅ ........ 11

២.១. ចក្ខុវិស័យ ........ 11

២.២. គោលបំណង ........ 11

២.៣. គោលដៅ ........ 11

៣. សមាសភាគ និងលទ្ធផលរំពឹងទុក ........ 12

ជំពូកទី២ សមាសភាគនានានៃផែនការអនុវត្តការងារគណនេយ្យភាពសង្គមដំណាក់កាលទី៣ ........ 20

សមាសភាគទី១÷ ការដឹកនាំ ការសម្របសម្រួល និងការគាំទ្រការងារគណនេយ្យភាពសង្គម ........ 20

សមាសភាគទី២÷ យន្តការគណនេយ្យភាពសង្គមរបស់រដ្ឋបាលមូលដ្ឋាន ........ 28

សមាសភាគទី ៣ ÷ ការអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គម ........ 33

សមាសភាគទី ៤ ÷ ការធ្វើសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងផែនការរបស់រដ្ឋបាលមូលដ្ឋាន ........ 40

សមាសភាគទី ៥ ÷ ការអនុវត្ត និងការពង្រីកគណនេយ្យភាពសង្គមនៅតាមរដ្ឋបាលមូលដ្ឋាន ........ 44

ជំពូកទី៣ ការគ្រប់គ្រង និងការអនុវត្តផែនការ ........ 49

១. ការអនុវត្ត ........ 49

២. ការត្រួតពិនិត្យ និងការវាយតម្លៃ ........ 50

៣. ការគ្រប់គ្រងហានិភ័យ ........ 50

ជំពូកទី ៤ ផែនការថវិកា ........ 53

១. ការប៉ាន់ស្មានចំណាយ ........ 53

២. ប្រភពថវិកា ........ 53

ជំពូកទី ៥ សេចក្តីសន្និដ្ឋាន ........ 55

# ជំពូកទី១
# ទិដ្ឋភាពទូទៅ

## ១. សេចក្តីផ្តើម

គណៈកម្មាធិការជាតិសម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) បានរៀបចំ និងដាក់ឱ្យអនុវត្ត "**ផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គមសម្រាប់ ការអភិវឌ្ឍប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**" ដែលបានអនុម័តនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣។ ផែនការយុទ្ធសាស្ត្រនេះត្រូវបានអនុវត្តតាមរយៈផែនការអនុវត្តគណនេយ្យភាពសង្គមតាមដំណាក់កាលៗ ដែលក្នុងនោះរួមមាន "**ផែនការអនុវត្តគណនេយ្យភាពសង្គមតាមដំណាក់កាលទី១**" (ISAF-I) ដែលបានអនុវត្តពីឆ្នាំ២០១៦ ដល់ ២០១៨ និង "**ផែនការអនុវត្តគណនេយ្យភាពសង្គមតាមដំណាក់កាលទី២**" (ISAF-II) ដែលបានអនុវត្តពីឆ្នាំ២០១៩-២០២៥។

គណនេយ្យភាពសង្គម គឺជាផ្នែកដ៏សំខាន់មួយនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលមានគោលបំណងពង្រឹងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដោយមានការចូលរួមពីប្រជាពលរដ្ឋ ស្របតាមចក្ខុវិស័យនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលផ្តោតលើការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យទំនើប ធន់មាំ មានស្វ័យភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងមានសមត្ថភាពក្នុងការឆ្លើយតបនឹងតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋ ជាពិសេសក្រុមជនងាយរងគ្រោះប្រកបដោយបរិយាបន្ន និងសមធម៌សង្គម។

ការអនុវត្តគណនេយ្យភាពសង្គម គឺជាការចូលរួមចំណែកអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីផ្សារភ្ជាប់ស្ថាប័នរដ្ឋដែលជា "**ផ្នែកផ្គត់ផ្គង់**" ជាមួយនឹងប្រជាពលរដ្ឋដែលជា "**ផ្នែកតម្រូវការ**" ដើម្បីលើកកម្ពស់ការប្រាស្រ័យទាក់ទង និងការចូលរួមប្រកបដោយស្មារតីស្ថាបនារវាងរដ្ឋបាលមូលដ្ឋាន អង្គភាពផ្តល់សេវាជាមួយនឹងប្រជាពលរដ្ឋនិងសហគមន៍មូលដ្ឋាន។

ការអនុវត្តការងារគណនេយ្យភាពសង្គមបានផ្តល់ឱកាសឱ្យប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋានទទួលបានព័ត៌មានចាំបាច់នានា ចូលរួមបញ្ចេញមតិ កំណត់បញ្ហាប្រឈមនិងតម្រូវការនានា តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់ត្រឡប់លើការបំពេញការងារ និងការផ្តល់សេវារបស់រដ្ឋបាលមូលដ្ឋាន និងអង្គភាពផ្តល់សេវានានា។ តាមរយៈការអនុវត្តគណនេយ្យភាពសង្គមបានបង្កើត និងពង្រឹងយន្តការជាច្រើនសម្រាប់ការផ្តល់ព័ត៌មាន ការតាមដាន ការត្រួតពិនិត្យលើការផ្តល់សេវាសាធារណៈ ការប្រមូលមតិយោបល់ពីប្រជាពលរដ្ឋ និងការរៀបចំផែនការសកម្មភាពរួម ស្តីពីការងារគណនេយ្យភាពសង្គម (JAAP) ដើម្បីដោះស្រាយ បញ្ហាប្រឈម និងឆ្លើយតបទៅនឹងតម្រូវការដែលបានលើកឡើងដោយប្រជាពលរដ្ឋ។ ឧបករណ៍សំខាន់ៗដែលបានប្រើប្រាស់ក្នុងក្របខណ្ឌនៃគណនេយ្យភាព រួមមាន ផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4C) ការពិនិត្យវាយតម្លៃដោយខ្លួនឯងរបស់អង្គភាពផ្តល់សេវា ការពិនិត្យវាយតម្លៃដោយប្រជាពលរដ្ឋ កិច្ចប្រជុំពិភាក្សារវាងអង្គភាពផ្តល់សេវានិងប្រជាពលរដ្ឋ និងការកំណត់ផែនការ

សកម្មភាពរួម ស្ដីពីការងារគណនេយ្យភាពសង្គម (JAAP) បានក្លាយជាឧបករណ៍ដ៏មានសារសំខាន់ក្នុងការផ្សារភ្ជាប់ការចូលរួម និងសំឡេងរបស់ប្រជាពលរដ្ឋទៅនឹងការកែលម្អការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

ក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងមកនេះ ការអនុវត្តគណនេយ្យភាពសង្គមបានវិវឌ្ឍពីការពឹងផ្អែកជាចម្បងលើការគាំទ្រពីគម្រោងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលទៅជាការអនុវត្តដែលមានការចូលរួម និងការទទួលខុសត្រូវកាន់តែច្រើនពីក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការរៀបចំ "**ផែនការអនុវត្តការងារគណនេយ្យភាពសង្គមដំណាក់កាលទី៣**" គឺដើម្បីផ្ដល់ផែនទីតម្រង់ទិសក្នុងការជំរុញការអនុវត្តការងារគណនេយ្យភាពសង្គមពីឆ្នាំ ២០២៦-២០៣០ ក្នុងបរិបទថ្មីបន្ទាប់ពី "ផែនការគណនេយ្យភាពសង្គមដំណាក់កាលទី២"ត្រូវបានបញ្ចប់នៅចុងឆ្នាំ២០២៥។ ការអនុវត្តការងារគណនេយ្យភាពសង្គមក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ ក្រោមការដឹកនាំសម្របសម្រួលរបស់ គ.ជ.អ.ប. ដោយមានកិច្ចសហការ និងការចូលរួមពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ សហគមន៍ អង្គការសង្គមស៊ីវិល អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ បានបង្កើតសមិទ្ធផលជាច្រើនសម្រាប់ធ្វើជាមូលដ្ឋានក្នុងការលើកកម្ពស់គណនេយ្យភាពសង្គមឱ្យកាន់តែល្អប្រសើរឡើង។

### ១.១. សមិទ្ធផលសំខាន់ៗ

#### ១.១.១ ការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងការឆ្លើយតបរបស់រដ្ឋបាលមូលដ្ឋាន និងអង្គភាពផ្ដល់សេវា

ការអនុវត្តគណនេយ្យភាពសង្គមបានបង្កើតសមិទ្ធផលសំខាន់ៗទាំង**ផ្នែកផ្គត់ផ្គង់** និង**ផ្នែកតម្រូវការ**។ **ក្នុងផ្នែកផ្គត់ផ្គង់** រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្ដល់សេវា រួមមាន រដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាព និងសាលាបឋមសិក្សាបានលើកកម្ពស់ការផ្ដល់ព័ត៌មានជាសាធារណៈ តាមរយៈផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ(I4C)ដែលបានដាក់បញ្ចូលនូវព័ត៌មានចាំបាច់សំខាន់ៗ និងងាយយល់ពាក់ព័ន្ធនឹងថវិកា ស្ដង់ដាសេវា និងលទ្ធផលការងារ។ ការកំណត់និងការអនុវត្តផែនការសកម្មភាពរួម ស្ដីពីការងារគណនេយ្យភាពសង្គម (JAAP) ក៏បានផ្សារភ្ជាប់អាទិភាពដែលប្រជាពលរដ្ឋបានលើកឡើងជាមួយការរៀបចំផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលមូលដ្ឋានដែលបានចូលរួមចំណែកដល់ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងលក្ខខណ្ឌនានានៃការផ្ដល់សេវាសាធារណៈឱ្យកាន់តែមានភាពល្អប្រសើរឡើង។

លទ្ធផលនៃការវាយតម្លៃឆ្នាំ២០២៤ បានបង្ហាញឱ្យឃើញថា ប្រព័ន្ធ និងយន្តការដែលបានបង្កើតឡើងសម្រាប់គាំទ្រ និងអនុវត្តគណនេយ្យភាពសង្គមមានភាពសមស្រប និងមានការទទួលស្គាល់ខ្ពស់ពីភាគីពាក់ព័ន្ធ។ ប្រមាណ ៩៦% នៃមន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋដែលបានចូលរួមវាយតម្លៃបានបង្ហាញទស្សនៈយល់ឃើញថា យន្តការគណនេយ្យភាពសង្គមដែលបានបង្កើតឡើងមានតួនាទី និងការទទួលខុសត្រូវសមស្រប និងមានការពេញចិត្តចំពោះការអនុវត្តតាមយន្តការទាំងនេះ។ នៅថ្នាក់រាជ

ធានី ខេត្ត និងក្រុង ស្រុក ក្រុមការងារគណនេយ្យភាពសង្គមត្រូវបានបង្កើត និងពង្រឹងសមត្ថភាពជាបន្តបន្ទាប់ តាមរយៈការបណ្តុះបណ្តាល ការណែនាំតម្រង់ទិស និងការគាំទ្របច្ចេកទេស។

ក្នុង**ផ្នែកតម្រូវការ** ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការតាមដាន និងវាយតម្លៃសេវាសាធារណៈមានការកើនឡើងយ៉ាងល្អប្រសើរ។ ផ្អែកតាមការវាយតម្លៃឆ្នាំ២០២៤បានបង្ហាញឱ្យឃើញថា ប្រមាណ ៨០%នៃអង្គភាពផ្តល់សេវាបានចូលរួមវាយតម្លៃដោយខ្លួនឯង ហើយប្រជាពលរដ្ឋប្រមាណ៨០,០០០នាក់ ដែលក្នុងនោះប្រមាណ៧០%ជាស្ត្រី បានចូលរួមក្នុងកិច្ចប្រជុំវាយតម្លៃគុណភាពសេវា និងកំណត់បញ្ហា និងតម្រូវការ ដើម្បីរៀបចំផែនការសកម្មភាពរួម ស្តីពីការងារគណនេយ្យភាពសង្គម (JAAP)។ ប្រមាណ ៩៥% នៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋបានទទួលស្គាល់អំពីសារៈសំខាន់នៃការវាយតម្លៃដោយខ្លួនឯង និងកិច្ចប្រជុំវាយតម្លៃគុណភាពសេវា និង៨៨% នៃប្រជាពលរដ្ឋបានយល់ថា ផែនការសកម្មភាពរួម ស្តីពីការងារគណនេយ្យភាព (JAAP) បានឆ្លុះបញ្ចាំងពីបញ្ហាប្រឈម និងតម្រូវការរបស់ខ្លួន។

សមិទ្ធផលដ៏មានសារៈសំខាន់នៃការអនុវត្តការងារគណនេយ្យភាពសង្គម គឺការកែលម្អគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។ ការវាយតម្លៃឆ្នាំ២០២៤បានបង្ហាញថា ៨៤% នៃអង្គភាពផ្តល់សេវាដែលបានវាយតម្លៃបានបំពេញតាមស្តង់ដាសំខាន់ៗរបស់ជាតិ ហើយប្រជាពលរដ្ឋប្រមាណ ៩៣% បានបង្ហាញពីការពេញចិត្តចំពោះលទ្ធផល និងការអនុវត្តរបស់អង្គភាពផ្តល់សេវា ព្រមទាំងបានយល់ថា គុណភាព បរិមាណ និងប្រសិទ្ធភាពនៃសេវាបានល្អប្រសើរឡើង បើប្រៀបធៀបនឹងមុនពេលនៃការអនុវត្តគណនេយ្យភាពសង្គម។ ប្រមាណ ៩៤% នៃប្រជាពលរដ្ឋយល់ថា គណនេយ្យភាពសង្គមបានរួមចំណែកដោយផ្ទាល់ដល់ការកែលម្អការផ្តល់សេវាសាធារណៈ។

នៅក្នុងការអនុវត្តជាក់ស្តែង ផែនការសកម្មភាពរួម ស្តីពីការងារគណនេយ្យភាពសង្គម (JAAP) បានក្លាយជាមធ្យោបាយសម្រាប់បម្លែងមតិយោបល់ និងតម្រូវការរបស់ប្រជាពលរដ្ឋទៅជាសកម្មភាពកែលម្អសេវា។ ការវាយតម្លៃឆ្នាំ២០២៤បានបង្ហាញថា ក្នុងឆ្នាំ២០២៣ ប្រមាណ៧៧%នៃផែនការសកម្មភាពរួម ស្តីពីការងារគណនេយ្យភាពសង្គម (JAAP) ដែលបានកំណត់ ត្រូវបានយកទៅអនុវត្ត ឬកំពុងអនុវត្ត ហើយសកម្មភាពទាំងនេះត្រូវបានគាំទ្រដោយធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នរដ្ឋពាក់ព័ន្ធនានា។

សមិទ្ធផលទាំងនេះបានបង្ហាញថា គណនេយ្យភាពសង្គមមិនមែនជាយន្តការសម្រាប់តែការផ្តល់ព័ត៌មាន ឬប្រមូលមតិយោបល់ពីប្រជាពលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែជាយន្តការមួយដែលជួយឱ្យរដ្ឋបាលមូលដ្ឋាន និងអង្គភាពផ្តល់សេវាយល់កាន់តែច្បាស់អំពីបញ្ហារបស់ប្រជាពលរដ្ឋ កែលម្អការឆ្លើយតប បង្កើនគុណភាពសេវា និងពង្រឹងទំនុកចិត្តរបស់ប្រជាពលរដ្ឋចំពោះរដ្ឋបាលមូលដ្ឋាន។ ជាពិសេស ការអនុវត្តការងារគណនេយ្យភាពសង្គមនេះបានផ្តល់ឱកាសឱ្យស្ត្រី ជនងាយរងគ្រោះ និងជនមានពិការភាព ចូលរួមក្នុងដំណើរការអភិបាលកិច្ច និងទទួលបានសេវាដែលឆ្លើយតបនឹងតម្រូវការរបស់ខ្លួនកាន់តែល្អប្រសើរ។

ជារួម ការវាយតម្លៃឆ្នាំ២០២៤ បានកត់សម្គាល់ឃើញថា មានការកែលម្អសេវាសម្រាប់ក្រុមងាយរងគ្រោះ រួមទាំងការជួយបំពេញពាក្យស្នើសុំ និងការរៀបចំមធ្យោបាយសមស្របសម្រាប់ជនមានពិការភាព មនុស្សចាស់នៅរដ្ឋបាលឃុំ សង្កាត់ មណ្ឌលសុខភាព និងសាលារៀនជាដើម។

### ១.១.២. ការរៀបចំលិខិតបទដ្ឋានគតិយុត្ត

ផ្អែកតាមការវិវឌ្ឍនៃគណនេយ្យភាពសង្គមពីមួយដំណាក់កាលទៅមួយដំណាក់កាលបានឈានទៅការបង្កើតយន្តការស្ថាប័ន និងលិខិតបទដ្ឋាន គតិយុត្តកាន់តែច្បាស់ក្នុងក្របខណ្ឌកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។ ជាក់ស្តែង ក្នុងរយៈពេលកន្លងមក ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំពាក់ព័ន្ធនឹងការអនុវត្តគណនេយ្យភាពសង្គម ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ ជាអាទិ៍ ផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គមឆ្នាំ២០១៣ ផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី១ និងដំណាក់កាលទី២ សេចក្តីសម្រេចពាក់ព័ន្ធនឹងការបង្កើតយន្តការដឹកនាំ និងសម្របសម្រួលគណនេយ្យភាពសង្គមនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ព្រមទាំងឯកសារណែនាំស្តីពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមការងារ និងមន្ត្រីទទួលបន្ទុកគណនេយ្យភាពសង្គមជាដើម។ ជាពិសេសការដាក់ចេញនូវអនុក្រឹត្យលេខ១៥៣ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់ អនុក្រឹត្យលេខ ១៥៤ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ដែលបានកំណត់ឱ្យរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុកមានថវិកាសម្រាប់ការផ្តល់សេវាសង្គម និងអនាម័យបរិស្ថាន និងសារាចរណ៍អន្តរក្រសួងលេខ០០៧រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃស្តីពីការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាសេវាសង្គម និងអនាម័យបរិស្ថាននៃមូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុកដែលបានអនុញ្ញាតឱ្យរដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុកអាចប្រើប្រាស់ថវិកាសម្រាប់គាំទ្រដល់សកម្មភាពគណនេយ្យភាពសង្គមនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ការអនុញ្ញាតតាមផ្លូវច្បាប់ឱ្យរដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុកប្រើប្រាស់ថវិកាឃុំ សង្កាត់ និងថវិកាក្រុង ស្រុកសម្រាប់គាំទ្រសកម្មភាពគណនេយ្យភាពសង្គម ជាសញ្ញាបង្ហាញពីការលើកកម្ពស់ភាពម្ចាស់ការរបស់រដ្ឋបាលមូលដ្ឋាន។ ក្នុងឆ្នាំ២០២៤ ឃុំ សង្កាត់ចំនួន ៩៣៨ ក្នុងចំណោម ១.៦៥២ ឬ ៥៧% បានបែងចែកថវិកាសម្រាប់គាំទ្រសកម្មភាពគណនេយ្យភាពសង្គមសរុបចំនួន៥៤៣.៩៧០ ដុល្លាអាមេរិក។ ចំនួនឃុំ សង្កាត់ដែលបានបែងចែកថវិកាសម្រាប់គាំទ្រគណនេយ្យភាពសង្គមបានកើនដល់១.១០១ ឬ ៦៧% ក្នុងឆ្នាំ២០២៥ដែលមានថវិកាសរុប៩០៣.៨៤៨ដុល្លាអាមេរិក និងបន្តកើនដល់១.២០៤ឃុំ សង្កាត់ ឬ ៧៣% ក្នុងឆ្នាំ២០២៦ ដែលមានថវិកាសរុបចំនួន១.១២៧.៤៧៧ ដុល្លារអាមេរិក។ និន្នាការនេះបង្ហាញពីការផ្លាស់ប្តូរដ៏សំខាន់ពីការពឹងផ្អែកលើធនធានពីខាងក្រៅ ឬពីគម្រោងគាំទ្រដោយដៃគូអភិវឌ្ឍន៍ទៅការប្រើប្រាស់ធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗ។

### ១.១. ៣. ការបង្កើត និងពង្រឹងយន្តការគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ការអនុវត្តគណនេយ្យភាពសង្គមបានបង្កើតនូវយន្តការដឹកនាំ សម្របសម្រួល តាមដាន ត្រួតពិនិត្យ និងគាំទ្រការអនុវត្តនៅគ្រប់កម្រិតថ្នាក់។ នៅថ្នាក់ជាតិ មានគណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការ

យុទ្ធសាស្ត្រគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ (គ.គ.អ.ស) ក្រុមការងារបច្ចេកទេសគណនេយ្យភាពសង្គម និងក្រុមការងារគណនេយ្យភាពសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ដែលដើរតួនាទីក្នុងការរៀបចំគោលការណ៍ណែនាំ ការបណ្តុះបណ្តាល តាមដាន ត្រួតពិនិត្យ និងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ នៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ក្រុមការងារគណនេយ្យភាពសង្គម និងមន្ត្រីទទួលបន្ទុកគណនេយ្យភាពសង្គមត្រូវបានបង្កើត និងពង្រឹងសមត្ថភាព ដើម្បីធានាដល់ការសម្របសម្រួលរវាងផ្នែកផ្គត់ផ្គង់ជាមួយនឹងផ្នែកតម្រូវការ។

ការពង្រឹងយន្តការទាំងនេះបានធ្វើឱ្យការអនុវត្តគណនេយ្យភាពសង្គមអាចពង្រីកវិសាលភាពបានជាបន្តបន្ទាប់។ នៅថ្នាក់ឃុំ សង្កាត់ គណនេយ្យភាពសង្គមត្រូវបានពង្រឹង និងពង្រីកការអនុវត្តជាបន្តបន្ទាប់ដែលគិតមកដល់ឆ្នាំ២០២៦នេះមានរដ្ឋបាលឃុំ សង្កាត់ចំនួន១.៥៥០ ស្មើនឹង៩៤%នៃឃុំ សង្កាត់ទូទាំងប្រទេសបាននិងកំពុងអនុវត្តគណនេយ្យភាពសង្គម ដោយគ្របដណ្តប់លើការផ្តល់សេវាសំខាន់ៗចំនួន៣ប្រភេទ គឺសេវារបស់រដ្ឋបាលឃុំ សង្កាត់ សេវាមណ្ឌលសុខភាពដែលចូលរួមអនុវត្តដោយមណ្ឌលសុខភាពចំនួន១.២៥៦ ស្មើនឹង៩៦%នៃមណ្ឌលសុខភាពទូទាំងប្រទេស និងសេវាសាលាបឋមសិក្សាដែលចូលរួមអនុវត្តដោយសាលាសិក្សាចំនួន៩.៦២២ស្មើនឹង៩៤%នៃសាលាបឋមសិក្សាទូទាំងប្រទេស។ នៅថ្នាក់ក្រុង ស្រុក ខណ្ឌ គណនេយ្យភាពសង្គមបានចាប់ផ្តើមអនុវត្តសាកល្បងពីឆ្នាំ២០១៩ និងបានពង្រឹង និងពង្រីកជាបន្តបន្ទាប់ដែលគិតមកដល់ឆ្នាំ២០២៦នេះមានរដ្ឋបាលក្រុង ស្រុកចំនួន៥៤ ស្មើ២៦% នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ដោយផ្តោតលើការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ជាមួយនឹងការពង្រឹងយន្តការ និងប្រព័ន្ធគណនេយ្យភាពសង្គម ក៏មានការអភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់ឧបករណ៍ និងប្រព័ន្ធឌីជីថល ដើម្បីគាំទ្រការគ្រប់គ្រងទិន្នន័យ ការផ្សព្វផ្សាយព័ត៌មាន ការរៀនសូត្រ និងការចូលរួមរបស់ប្រជាពលរដ្ឋ។ ក្នុងនោះ រួមមានការបង្កើតវេទិកា e-Learning ស្តីពីគណនេយ្យភាពសង្គម ការបង្កើតវេទិកាឌីជីថលសម្រាប់ការរៀនសូត្រពីគ្នា ការធ្វើបច្ចុប្បន្នភាព និងពង្រីកការប្រើប្រាស់ប្រព័ន្ធទិន្នន័យ ISAF និងកម្មវិធីទូរសព្ទដៃ ព្រមទាំងការអភិវឌ្ឍប្រព័ន្ធ Digital Scorecard សម្រាប់វាយតម្លៃលទ្ធផលការផ្តល់សេវា និងរៀបចំផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (JAAP)។ ឧបករណ៍ទាំងនេះបានរួមចំណែកពង្រឹងការប្រមូល និងវិភាគទិន្នន័យ ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ និងការប្រើប្រាស់ព័ត៌មានសម្រាប់ការតាមដាន និងកែលម្អការផ្តល់សេវាសាធារណៈ។

### ១.១.៤. ការកសាងសមត្ថភាព

ការកសាងសមត្ថភាពគឺជាធាតុសំខាន់មួយក្នុងការធានាឱ្យគណនេយ្យភាពសង្គមអាចបន្តអនុវត្តបានប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។ តាមរយៈការអនុវត្តការងារគណនេយ្យភាពសង្គម ក្រុមការងារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មន្ត្រីទទួលបន្ទុក អង្គភាពផ្តល់សេវា និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAF) ត្រូវបានបណ្តុះបណ្តាល និងទទួលការគាំទ្របច្ចេកទេសជាបន្តបន្ទាប់។ ការវាយតម្លៃឆ្នាំ២០២៤ បានបង្ហាញថា ក្រុមការងារគណនេយ្យភាពសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ

.ប. មានសមត្ថភាពល្អក្នុងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពដល់ក្រុមការងារនៅថ្នាក់ក្រោមជាតិ ហើយមន្ត្រីថ្នាក់ក្រោមជាតិមានការយល់ដឹង និងមានទំនុកចិត្តកាន់តែច្រើនក្នុងការអនុវត្តគណនេយ្យភាពសង្គម។

ក្នុងដំណាក់កាលថ្មីៗនេះ បានចាប់ផ្តើមបង្កើតប្រព័ន្ធរៀនសូត្រដែលមានលក្ខណៈចីរភាព នោះគឺការបង្កើតប្រព័ន្ធសិក្សាពីចម្ងាយ (e-Learning) ស្តីពីគណនេយ្យភាពសង្គមដើម្បីផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល និង CAF។ ការរៀបចំទស្សនកិច្ចផ្លាស់ប្តូរ និងចែករំលែកបទពិសោធន៍ (Peer Learning Exchanges/PLEs) ក៏ត្រូវបានប្រើជាយន្តការសម្រាប់ចែករំលែកមេរៀនបទពិសោធន៍ និងការអនុវត្តល្អរវាងរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ លើសពីនេះ ការសហការជាមួយសាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA) ដើម្បីបញ្ចូលប្រធានបទ ឬមាតិកាគណនេយ្យភាពសង្គមទៅក្នុងកម្មវិធីសិក្សាជាប្រចាំ គឺជាជំហានសំខាន់មួយឆ្ពោះទៅរកការរៀបចំប្រព័ន្ធ និងយន្តការស្ថាប័នអចិន្ត្រៃយ៍សម្រាប់ការអភិវឌ្ឍសមត្ថភាពពាក់ព័ន្ធនឹងគណនេយ្យភាពសង្គម។

### ១.១.៥. ក្រុមអ្នកស្ម័គ្រចិត្តអនុវត្តគណនេយ្យភាពសង្គម

សមិទ្ធផលដ៏សំខាន់មួយដែលកើតចេញពីការអនុវត្តគណនេយ្យភាពសង្គម គឺការបង្កើត និងការពង្រីកបាននូវក្រុមអ្នកស្ម័គ្រចិត្តអនុវត្តគណនេយ្យភាពសង្គម នោះគឺអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAF) និងបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAF-Network) ដែលបានដើរតួនាទីជាអ្នកសម្របសម្រួលរវាងប្រជាពលរដ្ឋជាមួយរដ្ឋបាលមូលដ្ឋាន និងអង្គភាពផ្តល់សេវា។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍បានជួយបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋ សម្របសម្រួល កិច្ចប្រជុំ និងការប្រមូលមតិយោបល់ ជួយឱ្យប្រជាពលរដ្ឋចូលរួមក្នុងការតាមដាន ត្រួតពិនិត្យការផ្តល់សេវា និងជួយភ្ជាប់បញ្ហាដែលប្រជាពលរដ្ឋលើកឡើងទៅនឹងដំណើរការឆ្លើយតបរបស់រដ្ឋបាលមូលដ្ឋាន និងអង្គភាពផ្តល់សេវា។

គិតត្រឹមឆ្នាំ២០២៦ មានអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដែលបានស្ម័គ្រចិត្តសរុបមានចំនួន៤.៧៤៨នាក់ ក្នុងនោះ៤.០៦៦នាក់នៅបន្តអនុវត្តការងារយ៉ាងសកម្ម។ ក្នុងចំណោមអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដែលកំពុងអនុវត្តការងារ មាន ៣.៥៦៨នាក់ ឬ ៨៨% បានទទួលវិញ្ញាបនបត្របញ្ជាក់ការសិក្សាពាក់ព័ន្ធនឹងគណនេយ្យភាពសង្គម។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ក៏ត្រូវបានទទួលស្គាល់ជាផ្លូវការដោយរដ្ឋបាលខេត្ត និងក្រុង ស្រុកមួយចំនួន ហើយមានរដ្ឋបាលខេត្ត និងក្រុង ស្រុកមួយចំនួនក៏បានប្រើប្រាស់ថវិការបស់រដ្ឋបាលខេត្ត ក្រុង ស្រុកសម្រាប់គាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ក្នុងការអនុវត្តគណនេយ្យភាពសង្គមក្នុងផ្នែកតម្រូវការ។

សមិទ្ធផលនេះបង្ហាញថា ក្រុមអ្នកអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍បានក្លាយជាធនធានសង្គមដ៏សំខាន់មួយសម្រាប់ការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្តរបស់រដ្ឋបាលមូលដ្ឋាន។ ទោះបីរដ្ឋបាលមូលដ្ឋានមួយចំនួនបាន

ប្រើប្រាស់ថវិការបស់ខ្លួនសម្រាប់គាំទ្រដល់ក្រុមអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ក៏ដោយ ក៏មិនគួរត្រូវបានចាត់ទុកថា ជាក្រុមដែលស្ថិតក្នុងផ្នែកផ្គត់ផ្គង់ ឬផ្នែកស្ថាប័នរដ្ឋនោះឡើយ។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ត្រូវរក្សាតួនាទីក្រុមអ្នកស្ម័គ្រចិត្ត និងមានភាពអព្យាក្រឹត ដែលអាចរក្សាទំនុកចិត្តរបស់ប្រជាពលរដ្ឋ និងជួយឱ្យពាំនាំសំឡេងរបស់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី យុវជន និងក្រុមជនងាយរងគ្រោះ ជនមានពិការភាព ជូនមករដ្ឋបាលមូលដ្ឋានដើម្បីដោះស្រាយ ឆ្លើយតបប្រកបដោយបរិយាបន្ន និងសមធម៌សង្គម។

## ១.២. បញ្ហាប្រឈមជាគន្លឹះ មេរៀន និងបទពិសោធន៍

ទោះបីជាមានសមិទ្ធផលគួរឱ្យកត់សម្គាល់ក៏ដោយ ក៏ការអនុវត្តគណនេយ្យភាពសង្គមនៅតែមានបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលចាំបាច់ត្រូវដោះស្រាយជាប្រព័ន្ធនៅក្នុងអំឡុងពេលនៃការអនុវត្តផែនការគណនេយ្យភាពសង្គមដំណាក់កាលទី៣ (ISAF-III)។ បញ្ហាប្រឈមជាគន្លឹះទាំងនោះរួមមានដូចខាងក្រោម៖

**ទីមួយ៖** គណនេយ្យភាពសង្គមមិនទាន់ត្រូវបានបញ្ចូលយ៉ាងពេញលេញទៅក្នុងប្រព័ន្ធគ្រប់គ្រងការងារ និងនីតិវិធីផ្តល់សេវារបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះបីផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គមបានរៀបចំ អនុម័ត និងដាក់ឱ្យអនុវត្តដោយ គ.ជ.អ.ប.ក៏ដោយ ក៏ការអនុវត្តនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួននៅតែយល់ថា ការអនុវត្តគណនេយ្យភាពសង្គមគឺជាកិច្ចការ ឬជាតម្រូវរបស់គម្រោងដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ ឬអង្គការសង្គមស៊ីវិល ជាជាងមុខងារឬកិច្ចការស្នូលរបស់ស្ថាប័នរដ្ឋក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ។

**ទីពីរ៖** ការភ្ជាប់ដំណើរការគណនេយ្យភាពសង្គមទៅនឹងដំណើរការកសាងផែនការ និងដំណើរការរៀបចំថវិការបស់រដ្ឋបាលមូលដ្ឋាននៅមិនទាន់មានភាពស៊ីសង្វាក់គ្នា។ ជាក់ស្តែង វដ្តនៃការរៀបចំផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (JAAP) និងវដ្តនៃការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលឃុំ សង្កាត់ (CIP) មិនទាន់ស្របគ្នា ដោយបានធ្វើឱ្យអាទិភាពមួយចំនួនដែលលើកឡើងដោយប្រជាពលរដ្ឋមិនអាចបញ្ចូលទៅក្នុងកម្មវិធីវិនិយោគបានទាន់ពេលវេលា។ ការវាយតម្លៃកន្លងមកបានកត់សម្គាល់ឃើញថា ដំណើរការកំណត់អាទិភាពក្នុងដំណើរការកសាងផែនការ និងកម្មវិធីវិនិយោគត្រូវបានរៀបចំមុនពេល ការកំណត់បាននូវផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (JAAP) ដែលជាហេតុធ្វើឱ្យឯកសារកម្មវិធីវិនិយោគ ត្រូវកែសម្រួលឡើងវិញ និងបង្កើតបញ្ហាអំពីប្រភពថវិកាសម្រាប់គាំទ្រដល់ការអនុវត្តសកម្មភាព JAAP។

**ទីបី៖** ទោះរដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុកបានប្រើប្រាស់ថវិកាសម្រាប់ការគាំទ្រដល់គណនេយ្យភាពសង្គមក៏ដោយ ក៏ថវិកាទាំងនេះនៅមិនទាន់គ្រប់គ្រាន់សម្រាប់ធានាការអនុវត្តពេញលេញ និងប្រកបដោយប្រសិទ្ធភាពនៅឡើយ។ នីតិវិធីសម្រាប់ការប្រើប្រាស់ថវិកាគាំទ្រការងារគណនេយ្យភាពទាំងនៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅមិនទាន់មានភាពច្បាស់លាស់។

**ទីបួន៖** បញ្ហាប្រឈមពាក់ព័ន្ធនឹងការកសាងសមត្ថភាពរបស់ស្ថាប័នអនុវត្ត ជាពិសេសការកសាងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះបីមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ត្រីអង្គភាពផ្តល់សេវាបានទទួលការបណ្តុះបណ្តាល មេរៀន និងបទពិសោធន៍ជាក់ស្តែងក៏ដោយ ក៏ទំនុកចិត្តក្នុងការអនុវត្តដំណើរការគណនេយ្យភាពសង្គមដោយខ្លួនឯងនៅមិនទាន់មានភាពជឿជាក់ ដោយត្រូវពឹងផ្អែកលើការគាំទ្រពីខាងក្រៅ ឬពីក្រុមអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAF)។ ការផ្លាស់ប្តូរមន្ត្រី និងអ្នកទទួលបន្ទុកគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិជាញឹកញាប់ បានធ្វើឱ្យបាត់បង់ចំណេះដឹង និងបទពិសោធន៍ដែលបានកសាងឡើងជាបន្តបន្ទាប់។

**ទីប្រាំ៖** ការសម្របសម្រួល និងការទទួលខុសត្រូវរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ក្នុងការរៀបចំកញ្ចប់ព័ត៌មាន I4C ការបញ្ចូលទិន្នន័យពាក់ព័ន្ធនឹងគណនេយ្យភាពសង្គមនៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ។

**ទីប្រាំមួយ៖** ហានិភ័យពាក់ព័ន្ធនឹងការបន្តនិរន្តរភាពការងាររបស់ក្រុមអ្នកស្ម័គ្រចិត្តសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAF) និង (CAF Network) បន្ទាប់ពីការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលត្រូវបានថយចុះ។ ប្រសិនបើមិនមានយន្តការមកជំនួសយន្តការដែលមាននាពេលបច្ចុប្បន្ននេះច្បាស់លាស់ទេ CAF អាចចុះខ្សោយ ឬឈប់ដំណើរការ ដែលប្រការនេះអាចប៉ះពាល់ដល់ការចូលរួមរបស់ប្រជាពលរដ្ឋ និងទំនុកចិត្តរបស់ប្រជាពលរដ្ឋដែលបានកសាងឡើងក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមក។ លើសពីនេះ ការរៀបចំឱ្យ CAF ក្លាយជាផ្នែកមួយនៃរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមិនគិតគូរពីភាពអព្យាក្រឹត និងតួនាទីជាអ្នកសម្របសម្រួលរបស់ប្រជាពលរដ្ឋនៅតាមសហគមន៍ អាចធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនមានការស្ទាក់ស្ទើរក្នុងការលើកឡើងនូវបញ្ហារសើប ឬបញ្ហាដែលពាក់ព័ន្ធនឹងគុណភាព និងភាពមិនប្រក្រតីនៃការសេវារបស់រដ្ឋបាលមូលដ្ឋាន និងអង្គភាពផ្តល់សេវា។ ដូច្នេះ ការរៀបចំផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី៣ (ISAF-III) ត្រូវផ្តោតលើការរក្សា CAF និង CAF Network ឱ្យមានភាពជាដៃគូជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ប៉ុន្តែមិនបាត់បង់ភាពអព្យាក្រឹត និងទំនុកចិត្តពីប្រជាពលរដ្ឋនៅតាមសហគមន៍ឡើយ។

ក្រៅពីបញ្ហាប្រឈមជាគន្លឹះ៖ ការអនុវត្តការងារគណនេយ្យភាពសង្គមនាពេលកន្លងមកក៏ប្រមូលបាននូវមេរៀន និងបទពិសោធន៍ល្អៗមួយចំនួន ជាអាទិ៍៖

**ទីមួយ៖** ការផ្តល់ព័ត៌មានដែលងាយយល់អំពីសិទ្ធិប្រជាពលរដ្ឋ ស្តង់ដាសេវា ថវិកា និងលទ្ធផលនៃការផ្តល់សេវា តាមរយៈ I4Cs ក្នុងទម្រង់សាមញ្ញ ងាយយល់ និងទាន់ពេលវេលា បានជួយឱ្យប្រជាពលរដ្ឋមានការយល់ដឹងកាន់តែប្រសើរ និងអាចចូលរួមតាមដាន និងផ្តល់មតិយោបល់យ៉ាងមានប្រសិទ្ធភាព។ បទពិសោធន៍ទាំងនេះបញ្ជាក់ថា ការប្រើប្រាស់ប្រព័ន្ធឌីជីថល និងព័ត៌មានតាមមធ្យោបាយផ្សេងៗ អាចជួយពង្រឹង និងពង្រីកចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការគណនេយ្យភាពសង្គម។

**ទីពីរ៖** ការសម្របសម្រួលល្អរវាង "ផ្នែកផ្គត់ផ្គង់" និង "ផ្នែកតម្រូវការ" គឺជាកត្តាសំខាន់ក្នុងការធានាឱ្យគណនេយ្យភាពសង្គមមានប្រសិទ្ធភាព។ ការចូលរួមរបស់ CAFs និង CAF Networks ក្នុងការ

ផ្សព្វផ្សាយព័ត៌មាន សម្របសម្រួលការតាមដានសេវា និងជួយរៀបចំការសន្ទនា កិច្ចប្រជុំពិភាក្សារវាងប្រជាពលរដ្ឋជាមួយរដ្ឋបាល និងអង្គភាពផ្តល់សេវាបានបង្កើនទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងប្រជាពលរដ្ឋ និងរដ្ឋបាលមូលដ្ឋាន និងអង្គភាពផ្តលសេវាដែលជាស្ថាប័នរដ្ឋ។ ដូច្នេះ ការពង្រឹងសមត្ថភាព និងការរក្សាភាពអព្យាក្រឹតរបស់ CAFs ព្រមទាំងកិច្ចសហការរវាងរដ្ឋបាលមូលដ្ឋាន អង្គភាពផ្តល់សេវា CAFs និងប្រជាពលរដ្ឋ គឺជាបទពិសោធន៍ល្អដែលគួរបន្តក្នុង ISAF-III។

**ទីបី៖** ការជជែកពិភាក្សាដោយផ្ទាល់នៅនឹងកន្លែងដែលឈានទៅកំណត់បាននូវបញ្ហាប្រឈម និងដំណោះស្រាយជាក់ស្តែង មានសារៈប្រយោជន៍ជាងការផ្តល់មតិយោបល់។ បទពិសោធន៍តាមរយៈ JAAP បង្ហាញថា មតិយោបល់ និងបញ្ហាដែលប្រជាពលរដ្ឋលើកឡើង អាចបម្លែងទៅជាសកម្មភាពរួមសម្រាប់កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងគុណភាពសេវាសាធារណៈ។ ទោះយ៉ាងនេះក្តី មេរៀនដ៏សំខាន់គឺ ត្រូវធានាឱ្យបានសកម្មភាពដែលបានព្រមព្រៀងក្នុង JAAP ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការ កម្មវិធីវិនិយោគ CIP/CDP និងគម្រោងថវិការបស់រដ្ឋបាលមូលដ្ឋាន ដើម្បីកុំឱ្យសម្មភាពទាំងនេះនៅត្រឹមតែជាឯកសារ។

**ទីបួន៖ ការធានាឱ្យមានការចូលរួមរបស់ស្ត្រី យុវជន ជនមានពិការភាព និងក្រុមងាយរងគ្រោះ ធ្វើឱ្យគណនេយ្យភាពសង្គមកាន់តែមានបរិយាបន្ន និងឆ្លើយតបនឹងតម្រូវការពិតប្រាកដ។** បទពិសោធន៍ ការអនុវត្តការងារគណនេយ្យភាពសង្គមបានបង្ហាញថា នៅពេលដែលក្រុមងាយរងគ្រោះត្រូវបានផ្តល់ឱកាសឱ្យចូលរួមផ្តល់មតិយោបល់ លើកសំណើសំណូមពរក្នុងកិច្ចពិភាក្សានានាជាមួយរដ្ឋបាលឃុំ សង្កាត់ និងអង្គភាពផ្តល់សេវា បញ្ហា សំណើសំណូមពរដែលលើកឡើងទោះនេះត្រូវបានដោះស្រាយ និងឆ្លើយតបបានកាន់តែច្បាស់។ បទពិសោធន៍បានបង្ហាញថា អ្នកសម្របសម្រួលសហគមន៍ CAF បានដើរតួនាទីសំខាន់ក្នុងកិច្ចការនេះ។ ដូច្នេះ មេរៀន បទពិសោធន៍នេះគួរត្រូវបានបន្តជាអាទិភាពក្នុង ISAF-III។

ទីប្រាំ. ភាពជោគជ័យនៃការអនុវត្តការងារគណនេយ្យភាពសង្គមរយៈពេលវែង គឺអាស្រ័យលើការលើកកម្ពស់ភាពម្ចាស់ការ ការធ្វើការស្ថាប័នភាវូបនីយកម្ម និងការប្រើប្រាស់ប្រព័ន្ធរដ្ឋជាប្រចាំ។ មេរៀនបទពិសោធន៍បានបង្ហាញថា ការបន្ស៊ី និងបញ្ចូលគណនេយ្យភាពសង្គមទៅក្នុងដំណើរការកសាងផែនការ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលឃុំ សង្កាត់ ការវិភាជថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់គាំទ្រដល់ដំណើរការអនុវត្តការងារគណនេយ្យភាពសង្គម បានធ្វើការងារគណនេយ្យភាពអាចអនុវត្តបន្ត ទោះបីការគាំទ្រពីគម្រោងនានាត្រូវបានបញ្ចប់។ អាស្រ័យហេតុនេះ ផែនការអនុវត្តគណនេយ្យភាពសង្គម ISAF-III គួរផ្តោតលើការធ្វើសមាហរណកម្ម ឬការបន្ស៊ីដំណើរការគណនេយ្យភាពសង្គមក្នុងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

### ១.៣. ដំណើរការរៀបចំ ISAF-III

មេរៀន បទពិសោធន៍ និងសមិទ្ធផលដែលសម្រេចបានក្នុងរយៈពេលកន្លងមក បានបញ្ជាក់យ៉ាងច្បាស់ថា គណនេយ្យភាពសង្គមមានសារៈសំខាន់ និងមានប្រសិទ្ធភាពក្នុងការពង្រឹងអភិបាលកិច្ច និងកែលម្អការផ្តល់សេវាសាធារណៈ។ ទោះជាយ៉ាងណា ដើម្បីធានាឱ្យមេរៀន បទពិសោធន៍ និងលទ្ធផលទាំង

នេះអាចរក្សាបាន និងបន្តកើនឡើងក្នុងរយៈពេលវែង គណនេយ្យភាពសង្គមត្រូវឈានទៅដំណាក់កាលថ្មីមួយ នៅគឺពី "**ការអនុវត្តដែលគាំទ្រដោយគម្រោង**" ទៅជា "ការអនុវត្តមុខងារ និងប្រព័ន្ធរបស់ស្ថាប័នរដ្ឋ"។ នេះគឺជាមូលហេតុចម្បង និងជាគោលការណ៍ស្នូលនៃការរៀបចំ ISAF-III។

ក្នុងន័យនេះ ISAF-III ត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋានដែលធានាថា គណនេយ្យភាពសង្គមត្រូវបានចាត់ទុកជាផ្នែកមួយនៃប្រព័ន្ធអភិបាលកិច្ច និងការផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាល មិនមែនជាសកម្មភាពដែលអនុវត្តតែនៅពេលដែលមានគម្រោង ឬថវិកាគាំទ្រពីដៃគូអភិវឌ្ឍន៍នោះឡើយ។ ដូច្នេះ ការរៀបចំ ISAF-III ត្រូវផ្តោតជាចម្បងលើការពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយកំណត់ឱ្យបានច្បាស់ថា ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិណាដែលត្រូវមានតួនាទីដឹកនាំ សម្របសម្រួល ត្រួតពិនិត្យ និងគាំទ្របច្ចេកទេស និងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិណាដែលមានតួនាទីជាស្ថាប័នអនុវត្ត។

ការរៀបចំISAF-III បានផ្តោតលើការផ្លាស់ប្តូរពីការពឹងផ្អែកពីគម្រោង និងកម្មវិធីដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិលឈានទៅរកប្រព័ន្ធដែលដឹកនាំដោយស្ថាប័នរដ្ឋ ដែលទាមទារឱ្យមានការផ្លាស់ប្តូរជាបណ្តើរៗទាំងបទដ្ឋានគតិយុត្ត យន្តការស្ថាប័ន សមត្ថភាព ហិរញ្ញប្បទាន និងយន្តការចូលរួមរបស់ប្រជាពលរដ្ឋ។ ក្នុងរយៈពេលអន្តរកាល ការគាំទ្រពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនៅតែមានតម្លៃសម្រាប់ការផ្តល់ជំនួយបច្ចេកទេស ការកសាងសមត្ថភាព ប៉ុន្តែក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ពង្រឹងភាពជាម្ចាស់ និងការទទួលខុសត្រូវជាចម្បង។

ជាមួយគ្នានេះ ការធ្វើស្ថាប័នភាវូបនីយកម្ម គឺជាចំណុចស្នូលដែលបានផ្តោតការយកចិត្តទុកដាក់ខ្ពស់នៃ ISAF-III។ ការស្ថាប័នភាវូបនីយកម្មមិនមែនមានន័យត្រឹមតែការបង្កើតក្រុមការងារ ឬចេញលិខិតទទួលស្គាល់នោះទេ ប៉ុន្តែមានន័យថា គោលការណ៍ ឧបករណ៍ និងដំណើរការគណនេយ្យភាពសង្គម ដូចជា I4C ការចូលរួមរបស់ប្រជាពលរដ្ឋ ការវាយតម្លៃអង្គភាពផ្តល់សេវាសេវា ការកំណត់JAAP ការឆ្លើយតបតាមមតិយោបល់ និងការរាយការណ៍ ត្រូវបានបញ្ចូលទៅក្នុងបទប្បញ្ញត្តិ នីតិវិធីកសាងផែនការ ថវិកា ប្រព័ន្ធតាមដាន និងវាយតម្លៃ និងប្រព័ន្ធបណ្តុះបណ្តាលរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ដើម្បីធានាឱ្យផែនការអនុវត្តការងារគណនេយ្យភាពសង្គមដំណាក់កាលទី៣នេះ មានលក្ខណៈគ្រប់ជ្រុងជ្រោយ លេខាធិការដ្ឋាន គ.ជ.អ.ប. បានសម្របសម្រួលដំណើរការរៀបចំផែនការអនុវត្តការងារគណនេយ្យភាពសង្គមដំណាក់កាលទី៣នេះ ដោយបានសិក្សាស្រាវជ្រាវលើឯកសារគតិយុត្ត ផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម ផែនការអនុវត្តគណនេយ្យភាពសង្គម កម្មវិធី/គម្រោង របាយការណ៍វឌ្ឍនភាព និងរបាយការណ៍វាយតម្លៃពាក់ព័ន្ធនានា ព្រមទាំងបានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ CAF អង្គការសង្គមស៊ីវិលពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធនានា និងបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីប្រមូលព័ត៌មាន ធាតុចូល មេរៀន បទពិសោធន៍ ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំ ISAF-III ។

## ២. ចក្ខុវិស័យ គោលបំណង គោលដៅ

### ២.១. ចក្ខុវិស័យ

ផែនការអនុវត្តការងារគណនេយ្យភាពសង្គមដំណាក់កាលទី៣ ត្រូវបានរៀបចំឡើងដើម្បីសម្រេចបាននូវចក្ខុវិស័យដ៏សំខាន់មួយគឺ "**ប្រជាពលរដ្ឋទទួលបានផលប្រយោជន៍ពីការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម**"។

### ២.២. គោលបំណង

ក្នុងការរួមចំណែកសម្រេចបាននូវចក្ខុវិស័យនេះ ផែនការអនុវត្តការងារគណនេយ្យភាពសង្គមដំណាក់កាលទី៣ មានគោលបំណងជាក់លាក់គឺ " **ពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ ដើម្បីជានាឱ្យរដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌវិភាជ គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានសម្រាប់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន សំដៅបម្រើផលប្រយោជន៍ប្រជាពលរដ្ឋ ជាពិសេសស្ត្រី យុវជន និងក្រុមជនងាយរងគ្រោះប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម**"។

### ២.៣. គោលដៅ

ដើម្បីធានាដល់ការសម្រេចបានគោលបំណងខាងលើ ផែនការអនុវត្តការងារគណនេយ្យភាពសង្គមដំណាក់កាលទី៣មានគោលដៅ "**លើកកម្ពស់ប្រសិទ្ធភាព ពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់ស្ថាប័នគាំទ្រ និងស្ថាប័នអនុវត្ត ដើម្បីធានានិរន្តរភាពនៃការអនុវត្តគណនេយ្យភាពសង្គម ព្រមទាំងពង្រីកវិសាលភាពការអនុវត្តឱ្យបានទូលំទូលាយទូទាំងប្រទេស**" តាមរយៈ៖

១. ការពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្តក្នុងការដឹកនាំ សម្របសម្រួល គាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងារគណនេយ្យភាពសង្គមនៅតាមរដ្ឋបាលមូលដ្ឋាន។

២. ការពង្រឹង និងធ្វើស្ថាប័នភាវូបនីយកម្មយន្តការអនុវត្តការងារគណនេយ្យភាពសង្គមនៅតាមរដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ។

៣. ការធ្វើសមាហរណកម្មដំណើរការ ឧបករណ៍ និងវិធីសាស្រ្តនៃការងារគណនេយ្យភាពសង្គមទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ព្រមទាំងគោលការណ៍ និងនីតិវិធីផ្តល់សេវារបស់រដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងអង្គភាពផ្តល់សេវាពាក់ព័ន្ធនានា។

៤. ការពង្រីកវិសាលភាពនៃការអនុវត្តគណនេយ្យភាពសង្គមនៅតាមរដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ដោយផ្អែកលើសមត្ថភាព ធនធាន និងយន្តការដែលបានកែលម្អជាបណ្តើរៗ។

៥. ការពង្រឹង និងធានានិរន្តរភាពក្រុមអ្នកសម្របសម្រួលគណនេយ្យភាពសង្គម (CAF) ដើម្បីបន្តគាំទ្រ និងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងការអនុវត្តការងារគណនេយ្យភាពសង្គមនៅមូលដ្ឋាន។

## ៣. សមាសភាគ និងលទ្ធផលរំពឹងទុក

ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី៣ ត្រូវបានរៀបចំឡើងដោយផ្អែកលើអាទិភាពជាយុទ្ធសាស្ត្រសំខាន់ៗ និងបែងចែកជាសមាសភាគចំនួន ៥ រួមមាន៖

**សមាសភាគទី១៖ ការដឹកនាំ ការសម្របសម្រួល និងការគាំទ្រការងារគណនេយ្យភាពសង្គម** ផ្តោតលើការពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងរដ្ឋបាលរាជធានី ខេត្ត ក្នុងការដឹកនាំ សម្របសម្រួល គាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារគណនេយ្យភាពសង្គម ព្រមទាំងការធ្វើស្ថាប័នភាវូបនីយកម្ម ដើម្បីធានានិរន្តរភាពនៃយន្តការគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត។

**សមាសភាគទី២៖ យន្តការអនុវត្តគណនេយ្យភាពសង្គមរបស់រដ្ឋបាលឃុំ សង្កាត់ក្រុង ស្រុក ខណ្ឌ** ផ្តោតលើការពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ ព្រមទាំងការធ្វើស្ថាប័នភាវូបនីយកម្មយន្តការអនុវត្តគណនេយ្យភាពសង្គមទៅក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងធានានិរន្តរភាពនៃការអនុវត្តគណនេយ្យភាពសង្គមក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលនីមួយៗ។

**សមាសភាគទី៣៖ ការអភិវឌ្ឍសមត្ថភាពអំពីការងារគណនេយ្យភាពសង្គម** ដោយផ្តោតទៅលើពង្រឹង និងធានានិរន្តរភាពយន្តការផ្តល់សេវាអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គមទាំងនៅថ្នាក់ជាតិ និងរដ្ឋបាលក្រោមជាតិ។

**សមាសភាគទី៤៖ ការធ្វើសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងផែនការរបស់រដ្ឋបាលមូលដ្ឋាន** ផ្តោតលើការធ្វើសមាហរណកម្មដំណើរការ វិធីសាស្ត្រ ទិន្នន័យ និងឧបករណ៍នៃគណនេយ្យភាពសង្គមទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ ដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងធានាឱ្យគណនេយ្យភាពសង្គមក្លាយជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រង និងអភិបាលកិច្ចរបស់រដ្ឋបាលមូលដ្ឋាន។

**សមាសភាគទី៥៖ ការអនុវត្ត និងការពង្រីកគណនេយ្យភាពសង្គមនៅតាមរដ្ឋបាលមូលដ្ឋាន** ផ្តោតលើការពង្រឹង ពង្រីក និងធានានិរន្តរភាពនៃការអនុវត្តការងារគណនេយ្យភាពសង្គមនៅតាមរដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ព្រមទាំងការលើកកម្ពស់គុណភាពនៃការចូលរួមរបស់ប្រជាពលរដ្ឋ និងការឆ្លើយតបរបស់រដ្ឋបាលមូលដ្ឋានចំពោះមតិយោបល់ និងតម្រូវការរបស់ប្រជាពលរដ្ឋ។

សមាសភាគនីមួយៗរួមមានសមិទ្ធផល លទ្ធផលរំពឹងទុក សកម្មភាពជាអាទិភាព សូចនាករ និងចំណុចដៅជាក់លាក់ដែលត្រូវអនុវត្ត ដើម្បីធានាការសម្រេចបាននូវគោលដៅ គោលបំណង និងចក្ខុវិស័យនៃផែនការអនុវត្តការងារគណនេយ្យភាពសង្គមដំណាក់កាលទី៣។

តារាងខាងក្រោមបង្ហាញអំពីក្របខ័ណ្ឌលទ្ធផលនៃផែនការអនុវត្តការងារគណនេយ្យភាពសង្គមដំណាក់កាលទី៣ រួមបញ្ចូលសូចនាករ និងចំណុចដៅ នៃលទ្ធផលរំពឹងទុក តាមសមាសភាគនីមួយៗ។

សេចក្តីព្រាង

## ក្របខ័ណ្ឌលទ្ធផលនៃផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី៣

| កូដ | ក្របខ័ណ្ឌលទ្ធផល | សូចនាករ និងចំណុចដៅ | | |
|---|---|---|---|---|
| | | សូចនាករ | ដើមគ្រាឆ្នាំ២០២៨ | ចុងគ្រាឆ្នាំ២០៣០ |
| | **ចក្ខុវិស័យ** ៖ ប្រជាពលរដ្ឋទទួលបានផលប្រយោជន៍ពីការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម។ | | | |
| | **គោលបំណង៖** ពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ ដើម្បីធានាឱ្យរដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌវិភាជន៍ គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានសម្រាប់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន សំដៅបម្រើផលប្រយោជន៍ប្រជាពលរដ្ឋ ជាពិសេសក្រុមជនងាយរងគ្រោះ ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម | – សន្ទស្សន៍ការចូលរួម<br>– សន្ទស្សន៍ការផ្តល់សេវា<br>– សន្ទស្សន៍តម្លាភាព<br>– សន្ទស្សន៍អភិបាលកិច្ច | – ០,៥៨<br>– ០,៦៩<br>– ០,៦២<br>– ០,៦៤ | – ០,៧៥<br>– ០,៧៩<br>– ០,៧២<br>– ០,៧៤ |
| | **គោលដៅ** ៖ លើកកម្ពស់ប្រសិទ្ធភាព ពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់ស្ថាប័នគាំទ្រ និងស្ថាប័នអនុវត្ត ដើម្បីធានានិរន្តរភាពនៃការអនុវត្តគណនេយ្យភាពសង្គម ព្រមទាំងពង្រីកវិសាលភាពការអនុវត្តឱ្យបានទូលំទូលាយទូទាំងប្រទេស តាមរយៈ៖<br>– ការពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្តក្នុងការដឹកនាំ សម្របសម្រួល គាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងារគណនេយ្យភាពសង្គមនៅតាមរដ្ឋបាលមូលដ្ឋាន។<br>– ការពង្រឹង និងធ្វើស្ថាប័នភាវូបនីយកម្មយន្តការអនុវត្តការងារគណនេយ្យភាពសង្គមនៅតាមរដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ។<br>– ការធ្វើសមាហរណកម្មដំណើរការ ឧបករណ៍ និងវិធីសាស្ត្រនៃការងារគណនេយ្យភាពសង្គមទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ព្រមទាំងគោលការណ៍ និងនីតិវិធីផ្តល់សេវារបស់រដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងអង្គភាពផ្តល់សេវាពាក់ព័ន្ធនានា។ | – %ឃុំ សង្កាត់មានសមត្ថភាព និងលទ្ធភាពអនុវត្តការងារគណនេយ្យភាពជាប្រចាំ<br>– %ក្រុង ស្រុក ខណ្ឌមានសមត្ថភាព និងលទ្ធភាពអនុវត្តការងារគណនេយ្យភាពជាប្រចាំ | | – ១០០%<br>– ១០០% |

| កូដ | ក្របខ័ណ្ឌលទ្ធផល | សូចនាករ និងចំណុចដៅ | | |
|---|---|---|---|---|
| | | សូចនាករ | ដើមគ្រាឆ្នាំ២០២៥ | ចុងគ្រាឆ្នាំ២០៣០ |
| | – ការពង្រីកវិសាលភាពនៃការអនុវត្តគណនេយ្យភាពសង្គមនៅតាមរដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ដោយផ្អែកលើសមត្ថភាព ធនធាន និងយន្តការដែលបានកែលម្អជាបណ្តើរៗ។<br>– ការពង្រឹង និងធានានិរន្តរភាពក្រុមអ្នកសម្របសម្រួលគណនេយ្យភាពសង្គម (CAF) ដើម្បីបន្តគាំទ្រ និងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងការអនុវត្តការងារគណនេយ្យភាពសង្គមនៅមូលដ្ឋាន។ | | | |
| **សមាសភាគទី១៖ ការដឹកនាំ ការសម្របសម្រួល និងការគាំទ្រគណនេយ្យភាពសង្គម** | | | | |
| | **សមិទ្ធផលរំពឹងទុក៖** ភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងរដ្ឋបាលរាជធានី ខេត្តក្នុងការដឹកនាំ សម្របសម្រួល និងគាំទ្រគណនេយ្យភាពសង្គមត្រូវបានពង្រឹង និងធ្វើស្ថាប័នភាវូបនីយកម្ម ដើម្បីធានាលើកកម្ពស់ប្រសិទ្ធភាព និងនិរន្តរភាពនៃការអនុវត្តគណនេយ្យភាពសង្គម។ | | | |
| ១.១. | **លទ្ធផលរំពឹងទុកទី១៖** យន្តការដឹកនាំ សម្របសម្រួល និងគាំទ្រការងារគណនេយ្យភាពសង្គមនៅថ្នាក់ជាតិត្រូវបានពង្រឹង និងធ្វើស្ថាប័នភាវូបនីយកម្ម ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងធានានិរន្តរភាពនៃការគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារគណនេយ្យភាពសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ | – %ក្រសួងពាក់ព័ន្ធបានបញ្ចូលការងារ SA ទៅក្នុងតួនាទី/ផែនការការងារ និងថវិការបស់ខ្លួន<br>– ការបង្កើតយន្តការថ្នាក់ជាតិការងារគណនេយ្យភាពសង្គមផ្អែកតម្រូវការ | | – ១០០%<br>– ដំណើរការ |
| | **លទ្ធផលរំពឹងទុកទី២៖** យន្តការដឹកនាំ សម្របសម្រួល និងគាំទ្រការងារគណនេយ្យភាពសង្គមនៅថ្នាក់រាជធានី ខេត្តត្រូវបានពង្រឹង និងធ្វើស្ថាប័នភាវូបនីយកម្ម ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងធានានិរន្តរភាពនៃការគាំទ្រ ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តគណនេយ្យភាពសង្គមរបស់រដ្ឋបាលមូលដ្ឋាន។ | – %រាជធានី ខេត្តបានបញ្ចូលយន្តការ SA ទៅក្នុងតួនាទី/អង្គភាព/ផែនការការងារ និងថវិការបស់ខ្លួន<br>– %រាជធានី ខេត្តបានបង្កើត និងទទួលស្គាល់បណ្តាញ CAF | – | – 100%<br>– 100% |

| កូដ | ក្របខ័ណ្ឌលទ្ធផល | សូចនាករ និងចំណុចដៅ | | |
|---|---|---|---|---|
| | | សូចនាករ | ដើមគ្រាឆ្នាំ២០២៤ | ចុងគ្រាឆ្នាំ២០៣០ |
| | **លទ្ធផលរំពឹងទុកទី៣៖** ប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់ការតាមដាន ត្រួតពិនិត្យ វាយតម្លៃការ និងប្រព័ន្ធឌីជីថលសម្រាប់ផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងគណនេយ្យភាពសង្គមត្រូវបានធ្វើបច្ចុប្បន្នភាព កែលម្អ និងដាក់ឱ្យដំណើរការប្រកបដោយប្រសិទ្ធភាព។ | – ចំនួនប្រព័ន្ធទិន្នន័យ និងប្រព័ន្ធឌីជីថលសម្រាប់ការងារគណនេយ្យភាពសង្គមដែលបានដាក់ឱ្យប្រើប្រាស់ | – ៤ | – .....? |
| | **លទ្ធផលរំពឹងទុកទី៤៖** កិច្ចសហការក្នុងភាពជាដៃគូរវាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ មានសមត្ថកិច្ចជាមួយ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋានត្រូវបានពង្រឹង ដើម្បីកៀរគរ និងប្រើប្រាស់ធនធាន ជំនាញ និងការចូលរួមគាំទ្រដល់ការអនុវត្តគណនេយ្យភាពសង្គមប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។ | – ចំនួនដៃគូអភិវឌ្ឍន៍ដែលបានចូលរួម និងគាំទ្រ ការងារគណនេយ្យភាពសង្គម | – ៤ | – ១០ |
| **សមាសភាគទី២៖ យន្តការអនុវត្តគណនេយ្យភាពសង្គមរបស់រដ្ឋបាលឃុំ សង្កាត់ក្រុង ស្រុក ខណ្ឌ** | | | | |
| | **សមិទ្ធផលរំពឹងទុក៖** ភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌក្នុងការរៀបចំ និងអនុវត្តគណនេយ្យភាពសង្គមត្រូវបានពង្រឹង និងធ្វើស្ថាប័នភាវូបនីយកម្ម ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងធានានិរន្តរភាពនៃការអនុវត្តគណនេយ្យភាពសង្គមក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលនីមួយៗ។ | | | |
| | **លទ្ធផលរំពឹងទុកទី១៖** យន្តការអនុវត្តការងារគណនេយ្យភាពសង្គមរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានពង្រឹង និងធ្វើស្ថាប័នភាវូបនីយកម្ម ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងធានានិរន្តរភាពការអនុវត្តគណនេយ្យភាពសង្គមក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ។ | – %ក្រុង ស្រុក ខណ្ឌបានបញ្ចូលយន្តការ SA ទៅក្នុងតួនាទី/អង្គភាព/ផែនការការងារ និងថវិការបស់ខ្លួន<br>– %ក្រុង ស្រុក ខណ្ឌបានបង្កើត និងទទួលស្គាល់បណ្តាញ CAF | – | – ១០០%<br>– ១០០% |
| | **លទ្ធផលរំពឹងទុកទី២៖** យន្តការអនុវត្តការងារគណនេយ្យភាពសង្គមរបស់រដ្ឋបាលឃុំ សង្កាត់ត្រូវបានពង្រឹង និងធ្វើស្ថាប័នភាវូបនីយកម្ម ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងធានានិរន្តរភាពការងារគណនេយ្យភាពសង្គក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗ។ | – %ឃុំ សង្កាត់បានបញ្ចូលយន្តការ SA ទៅក្នុងតួនាទីគណៈកម្មាធិការ ផែនការការងារ និងថវិការបស់ខ្លួន<br>– ចំនួន CAF ស្ម័គ្រចិត្តបម្រើការងារគណនេយ្យភាពសង្គមនៅតាមឃុំ សង្កាត់ | – ៤.១៣៦ | – ៦.៦០៨ |

| កូដ | ក្របខ័ណ្ឌលទ្ធផល | សូចនាករ និងចំណុចដៅ | | |
|---|---|---|---|---|
| | | សូចនាករ | ដើមគ្រាឆ្នាំ២០២៨ | ចុងគ្រាឆ្នាំ២០៣០ |
| **សមាសភាគទី៣៖ ការអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គម** | | | | |
| | **សមិទ្ធផលរំពឹងទុក៖** ប្រព័ន្ធ និងយន្តការអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គមត្រូវបានពង្រឹង និងធានានិរន្តរភាព ដើម្បីលើកកម្ពស់ចំណេះដឹង ជំនាញ និងសមត្ថភាពរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋក្នុងការអនុវត្តគណនេយ្យភាពសង្គម។ | | | |
| | **លទ្ធផលរំពឹងទុកទី១៖** យន្តការអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គមត្រូវបានពង្រឹង និងធ្វើស្ថាប័នភាវូបនីយកម្ម ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍសមត្ថភាពរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា។ | – ចំនួនក្រសួង ស្ថាប័នមានយន្តការ និងផែនការអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គមជាប្រចាំ<br>– % រាជធានី ខេត្តដែលមានយន្តការអភិវឌ្ឍសមត្ថភាពគណនេយ្យភាពសង្គមជាប្រចាំ | – | – |
| | **លទ្ធផលរំពឹងទុកទី២៖** ផែនការអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គមត្រូវបានរៀបចំ អនុម័ត និងដាក់ឱ្យអនុវត្តជាប្រចាំស្របតាមតម្រូវការរបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា។ | – ផែនការអភិវឌ្ឍសមត្ថភាពរួមអំពីគណនេយ្យភាពសង្គមនៅថ្នាក់ជាតិ<br>– % រាជធានី ខេត្តដែលមានផែនការអភិវឌ្ឍសមត្ថភាពគណនេយ្យភាពសង្គម | – | – អនុម័ត/អនុវត្តប្រចាំឆ្នាំ<br>– ១០០% |
| | **លទ្ធផលរំពឹងទុកទី៣៖** សមត្ថភាពរបស់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងអ្នកពាក់ព័ន្ធ និងសហគមន៍មូលដ្ឋានក្នុងការអនុវត្តគណនេយ្យភាពសង្គមត្រូវបានពង្រឹង។ | – % បុគ្គលិករាជធានី ខេត្តយល់ដឹងអំពីការងារគណនេយ្យភាពសង្គម<br>– % បុគ្គលិកក្រុង ស្រុក ខណ្ឌយល់ដឹងអំពីការងារគណនេយ្យភាពសង្គម<br>– % បុគ្គលិក/ក្រុមប្រឹក្សាឃុំ សង្កាត់យល់ដឹងអំពីការងារគណនេយ្យភាពសង្គម | – | – |

| កូដ | ក្របខ័ណ្ឌលទ្ធផល | សូចនាករ និងចំណុចដៅ | | |
|---|---|---|---|---|
| | | សូចនាករ | ដើមគ្រាឆ្នាំ២០២៨ | ចុងគ្រាឆ្នាំ២០៣០ |
| | | – % CAF យល់ដឹងអំពីការងារគណនេយ្យភាពសង្គម | | |
| **សមាសភាគទី៤៖ ការធ្វើសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងផែនការរបស់រដ្ឋបាលមូលដ្ឋាន** | | | | |
| | **សមិទ្ធផលរំពឹងទុក៖** ដំណើរការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌត្រូវបានកែលម្អ តាមរយៈការធ្វើសមាហរណកម្មវិធីសាស្ត្រ ទិន្នន័យ និងឧបករណ៍នៃគណនេយ្យភាពសង្គម ដើម្បីពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ និងធានានិរន្តរភាពនៃគណនេយ្យភាពសង្គម។ | | | |
| | **លទ្ធផលរំពឹងទុកទី១៖** ដំណើរការ វិធីសាស្ត្រ ទិន្នន័យ និងឧបករណ៍នៃគណនេយ្យភាពសង្គមត្រូវបានធ្វើសមាហរណកម្មទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ ដើម្បីពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ និងធានានិរន្តរភាពនៃការងារគណនេយ្យភាពសង្គម។ | – សេចក្ដីណែនាំស្ដីពីដំណើរការកសាងផែនការ និងកម្មវិធីវិនិយោគឃុំ សង្កាត់បានកែលម្អដោយបញ្ចូលSA | – | អនុម័ត/អនុវត្ត |
| | **លទ្ធផលរំពឹងទុកទី២៖** ដំណើរការ វិធីសាស្ត្រ ទិន្នន័យ ឧបករណ៍វិភាគទិន្នន័យនៃគណនេយ្យភាពសង្គមត្រូវបានធ្វើសមាហរណកម្មទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគពឆ្នាំរំកិល និងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធានាការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងនិរន្តរភាពការងារគណនេយ្យភាពសង្គម។ | – សេចក្ដីណែនាំស្ដីពីដំណើរការកសាងផែនការ និងកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌបានកែលម្អដោយបញ្ចូល SA | – | – អនុម័ត/អនុវត្ត |
| **សមាសភាគទី៥៖ ការអនុវត្ត និងការពង្រីកគណនេយ្យភាពសង្គមនៅតាមរដ្ឋបាលមូលដ្ឋាន** | | | | |
| | **សមិទ្ធផលរំពឹងទុក៖** ការអនុវត្តគណនេយ្យភាពសង្គមត្រូវបានពង្រឹង ពង្រីក និងធ្វើឱ្យមាននិរន្តរភាពនៅតាមរដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។ | | | |
| | **លទ្ធផលរំពឹងទុកទី១៖** គណនេយ្យភាពសង្គមត្រូវបានអនុវត្តនៅតាមរដ្ឋបាលឃុំ សង្កាត់ទូទាំងប្រទេសប្រកបដោយប្រសិទ្ធភាព ការចូលរួម និងនិរន្តរភាព។ | – %ឃុំ សង្កាត់អនុវត្តការងារគណេយ្យភាពសង្គមជាប្រចាំតាមសេចក្ដីណែនាំដែលបានកែលម្អ | – ៩៤% | – ១០០% |

| កូដ | ក្របខ័ណ្ឌលទ្ធផល | សូចនាករ និងចំណុចដៅ | | |
|---|---|---|---|---|
| | | សូចនាករ | ដើមគ្រាឆ្នាំ២០២៥ | ចុងគ្រាឆ្នាំ២០៣០ |
| | **លទ្ធផលរំពឹងទុកទី២៖** ការងារគណនេយ្យភាពសង្គមត្រូវបានអនុវត្តនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ប្រកបដោយប្រសិទ្ធភាព ការចូលរួម និងនិរន្តរភាព។ | – %ក្រុង ស្រុក ខណ្ឌអនុវត្តការងារគណេយ្យភាពសង្គមជាប្រចាំតាមសេចក្ដីណែនាំដែលបានកែលម្អ | – ៩៤% | – ១00% |
| | **លទ្ធផលរំពឹងទុកទី៣៖** អ្នកសម្របសម្រួលគណនេយ្យភាពសង្គម (CAF) និងបណ្ដាញ CAF ត្រូវបានពង្រឹង និងរៀបចំឱ្យមានតួនាទីសមស្រប ដើម្បីគាំទ្រការចូលរួមរបស់ប្រជាពលរដ្ឋ និងការអនុវត្តគណនេយ្យភាពសង្គមនៅតាមមូលដ្ឋានក្នុងបរិបទថ្មី។ | – ចំនួន CAF ដែលនៅស្ម័គ្រចិត្តបម្រើការងារតាមបរិបទថ្មី | – | – ៦.៦០៨ |

សេចក្ដីព្រាង

# ជំពូកទី២

## សមាសភាគនានានៃផែនការអនុវត្តការងារគណនេយ្យភាពសង្គមដំណាក់កាលទី៣

ជំពូកនេះ គឺជាជំពូកមួយដ៏មានសារៈសំខាន់នៃឯកសារផែនការអនុវត្តការងារគណនេយ្យភាពសង្គម ដំណាក់កាលទី៣ ពិពណ៌នាអំពីសមាសភាគចំនួន៥ ដែលត្រូវអនុវត្តក្នុងរយៈពេល៥ឆ្នាំខាងមុខ។

### សមាសភាគទី១៖ ការដឹកនាំ ការសម្របសម្រួល និងការគាំទ្រការងារគណនេយ្យភាពសង្គម

សនិទានភាព៖

ការអនុវត្តគណនេយ្យភាពសង្គមនាកន្លងមក បានបង្កើតមូលដ្ឋានសំខាន់ៗជាច្រើន រួមមាន ការបង្កើតយន្តការដឹកនាំ និងសម្របសម្រួលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការរៀបចំ និងការផ្សព្វផ្សាយព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs) ការអភិវឌ្ឍសមត្ថភាព និងការបង្កើតយន្តការចូលរួមរបស់ប្រជាពលរដ្ឋ ។ល។ សមិទ្ធផលទាំងនេះបានរួមចំណែកបង្កើនតម្លាភាព ការចូលរួមរបស់ប្រជាពលរដ្ឋ និងការឆ្លើយតបរបស់អង្គភាពផ្តល់សេវាចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ។

ទោះជាយ៉ាងណា ការអនុវត្តកន្លងមកនៅតែមានបញ្ហាប្រឈមមួយចំនួនដែលអាចប៉ះពាល់ដល់ប្រសិទ្ធភាព និងនិរន្តរភាពនៃការងារគណនេយ្យភាពសង្គម។ ជាពិសេស តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅមិនទាន់ត្រូវបានកំណត់ និងអនុវត្តបានច្បាស់លាស់។ រដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួននៅតែយល់ថា ការងារគណនេយ្យភាពសង្គមជាកិច្ចការបន្ថែមរបស់គម្រោង ជាជាងជាមុខងារពាក់ព័ន្ធនឹងការលើកកម្ពស់អភិបាលកិច្ចប្រចាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ លើសពីនេះ ការអនុវត្តគណនេយ្យភាពនៅមូលដ្ឋានមួយចំនួននៅតែពឹងផ្អែកយ៉ាងខ្លាំងទៅលើជំនួយបច្ចេកទេស និងហិរញ្ញប្បទានពីគម្រោងគាំទ្រដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល។

ដូច្នេះ ក្នុងដំណាក់កាលទី៣ ចាំបាច់ត្រូវផ្លាស់ប្តូរពីការអនុវត្តដែលផ្អែកលើការគាំទ្រពីខាងក្រៅ ទៅជាការអនុវត្តដែលដឹកនាំ និងគាំទ្រដោយប្រព័ន្ធរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថជាប្រចាំ។ ការផ្លាស់ប្តូរនេះទាមទារឱ្យមានការពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលរាជធានី ខេត្ត ព្រមទាំងការកំណត់តួនាទី និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់ ការពង្រឹងយន្តការសម្របសម្រួល ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និងការធ្វើស្ថាប័នភាវូបនីយកម្មការងារគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធ និងនីតិវិធីរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត។

ជាមួយគ្នានេះ ការដឹកនាំ និងការសម្របសម្រួលនៅថ្នាក់ជាតិត្រូវមានតួនាទីសំខាន់ក្នុងការធានាឱ្យមាន **គោលនយោបាយ លិខិតបទដ្ឋាន គោលការណ៍ណែនាំ ប្រព័ន្ធទិន្នន័យ និងយន្តការតាមដាន** ដែលមានភាពស៊ីសង្វាក់គ្នា និងអាចគាំទ្រការអនុវត្តគណនេយ្យភាពសង្គមទូទាំងប្រទេស។ ជាពិសេស ត្រូវពង្រឹងការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបញ្ចូលការងារគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធ

និងនីតិវិធីតាមវិស័យ រួមទាំងការផ្តល់គាំទ្រធនធានថវិកា ការគ្រប់គ្រង និងផ្សព្វផ្សាយ I4Cs និងការតាមដានគុណភាពសេវារបស់អង្គភាពផ្តល់សេវា។

ការពង្រឹងកិច្ចសហការជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន ក៏ជាកត្តាចាំបាច់ ដើម្បីប្រមូលផ្តុំចំណេះដឹង បទពិសោធន៍ ជំនាញ និងធនធានសម្រាប់គាំទ្រដល់ការអនុវត្តគណនេយ្យភាពសង្គមឱ្យមានគុណភាព និងអាចពង្រីកវិសាលភាពបានទៅទូទាំងប្រទេស។

ក្នុងន័យនេះ **សមាសភាគទី១** ត្រូវបានរៀបចំឡើងដើម្បីធានាថា ការងារគណនេយ្យភាពសង្គមមាន **ការដឹកនាំច្បាស់លាស់ ការសម្របសម្រួលមានប្រសិទ្ធភាព ការគាំទ្រដែលមាននិរន្តរភាព ប្រព័ន្ធព័ត៌មាន និងតាមដានដែលអាចទុកចិត្តបាន និងកិច្ចសហការជាដៃគូមានភាពរឹងមាំ និងរន្តរភាព**។ កត្តាទាំងនេះ គឺជាមូលដ្ឋានគ្រឹះសម្រាប់ជំរុញឱ្យសមាសភាគផ្សេងទៀតរបស់ ISAF-III អាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព និងជាពិសេសអាចធានាឱ្យការងារគណនេយ្យភាពសង្គមក្លាយជាផ្នែកមួយនៃប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាល មូលដ្ឋាន និងបន្តបានដោយមានភាពម្ចាស់ការរបស់ស្ថាប័នរដ្ឋនៅពេលអនាគត។

**សមិទ្ធផលរំពឹងទុក៖**

សមិទ្ធផលរំពឹងទុកនៃការដឹកនាំ ការសម្របសម្រួល និងការគាំទ្រការងារគណនេយ្យភាពសង្គម គឺ "**ភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងរដ្ឋបាលរាជធានី ខេត្ត ក្នុងការដឹកនាំ សម្របសម្រួល និងគាំទ្រគណនេយ្យភាពសង្គមត្រូវបានពង្រឹង និងធ្វើស្ថាប័នភាវូបនីយកម្ម ដើម្បីធានាលើកកម្ពស់ប្រសិទ្ធភាព និងនិរន្តរភាពនៃការអនុវត្តគណនេយ្យភាពសង្គម**"។

ដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកខាងលើ សមាសភាគទី១ បានកំណត់នូវលទ្ធផលរំពឹងទុកចំនួន០៤ រួមមាន ៖

**លទ្ធផលរំពឹងទុកទី ១.១ ៖** យន្តការដឹកនាំ សម្របសម្រួល និងគាំទ្រការងារគណនេយ្យភាពសង្គមនៅថ្នាក់ជាតិត្រូវបានពង្រឹង និងធ្វើស្ថាប័នភាវូបនីយកម្ម ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងធានានិរន្តរភាពនៃការគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារគណនេយ្យភាពសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទី១.១នេះ រួមមាន ៖

### សកម្មភាពជាអាទិភាព ១.១.១ ៖ ពង្រឹងការអនុវត្តតួនាទី និងភារកិច្ចរបស់ គ.គ.អ.ស.

ដើម្បីសម្រេចបាននូវសកម្មភាពជាអាទិភាពខាងលើ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- បន្តពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ "គណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ" ដូចជា ការពិនិត្យសម្រេចលើផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គណៈកម្មាធិការនេះ ដើម្បីដាក់បញ្ចូលក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ការរៀបចំកិច្ចប្រជុំប្រចាំឆមាសឱ្យបានទៀងទាត់ និងការចុះទស្សនកិច្ចសិក្សានៅមូលដ្ឋាន ការធានាឱ្យមានការអនុវត្តទាំងផ្នែកផ្គត់ផ្គង់

និងផ្នែកតម្រូវការនៃការងារគណនេយ្យភាព សង្គម ការកៀរគរការគាំទ្រដល់ការរៀបចំ និងការអនុវត្តការងារគណនេយ្យភាពសង្គម ការពិនិត្យ និងផ្តល់យោបល់សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គម ការពិនិត្យ ពិភាក្សា និងផ្តល់ការគោលការណ៍ណែនាំដល់ការពង្រឹង និងពង្រីកការអនុវត្តការងារគណនេយ្យភាពសង្គម និងការដោះស្រាយបញ្ហាប្រឈមនានា ការសម្របសម្រួលឱ្យមានការពិភាក្សា ពិគ្រោះយោបល់រវាងអ្នកពាក់ព័ន្ធដែលគាំទ្រផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងជានានិរន្តរភាពនៃការអនុវត្តការងារគណនេយ្យភាពសង្គម...។

- សិក្សាជម្រើសសមស្របសម្រាប់ការកែសម្រួល និងផ្ទេរតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ «គណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ» ទៅក្នុងតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់យន្តការ គ.ជ.អ.ប.។
- បន្តពង្រឹងការអនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមការងារបច្ចេកទេសគណនេយ្យភាពសង្គម រួមមានដូចជា ការពិនិត្យ និងផ្តល់យោបល់ផ្នែកបច្ចេកទេសលើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត ឯកសារបច្ចេកទេស ការចងក្រងមេរៀនបទពិសោធន៍ ការរៀបចំ និងធ្វើបច្ចុប្បន្នភាពផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋ (I4Cs) សំណើពង្រីកវិសាលភាព ការអភិវឌ្ឍសមត្ថភាព និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារគណនេយ្យភាពសង្គម។

### សកម្មភាពជាអាទិភាព ១.១.២ ៖ ពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.

ដើម្បីសម្រេចបាននូវសកម្មភាពជាអាទិភាពខាងលើ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- បន្តពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការគាំទ្រ និងការសម្របសម្រួលដល់ការរៀបចំ និងការអនុវត្តការងារគណនេយ្យភាពសង្គម រួមមានដូចជា ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រការងារគណនេយ្យភាពសង្គម ការសម្របសម្រួល និងពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ដើម្បីការកៀរគរការចូលរួម និងការគាំទ្រដល់ការអនុវត្តការងារគណនេយ្យភាពសង្គម ការរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គម ការអភិវឌ្ឍសមត្ថភាព រៀបចំធ្វើបច្ចុប្បន្នភាព និងផលិតផ្ទាំងព័ត៌មានសម្រាប់ផ្សព្វផ្សាយ I4Cs... ការរៀបចំ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យសម្រាប់ការតាមដាន ត្រួតពិនិត្យការងារគណនេយ្យភាពសង្គម និងប្រព័ន្ធឌីជីថលនានា)

### សកម្មភាពជាអាទិភាព ១.១.៣ ៖ ពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់យន្តការសម្របសម្រួលការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ

ដើម្បីសម្រេចបាននូវសកម្មភាពជាអាទិភាពខាងលើ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

– បន្តពង្រឹងការអនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកសម្របសម្រួលផ្នែកតម្រូវការនៅថ្នាក់ជាតិ (Demand-Side Coordinator) ដូចជា ការធ្វើទំនាក់ទំនង និងការសម្របសម្រួលជាមួយអង្គការសង្គមស៊ីវិល និងបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ក្នុងការប្រមូលព័ត៌មានអំពីវឌ្ឍនភាព និងប្រឈមនានាពាក់ព័ន្ធនឹងផ្នែកតម្រូវការនៃការងារគណនេយ្យភាពសង្គម ដើម្បីយកមកពិភាក្សា និងដោះស្រាយសិក្សាជម្រើស និងបង្កើតយន្តការគាំទ្រផ្នែកតម្រូវការនៃគណនេយ្យភាពសង្គមនៅថ្នាក់ជាតិ (ការបង្កើតក្រុមប្រឹក្សាយោបល់បច្ចេកទេសផ្នែកតម្រូវការនៃការងារគណនេយ្យភាពសង្គម Demand-Side Technical Advisory Group) ដែលមានសមាសភាពមកពីតំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល និងតំណាងបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍រាជធានី ខេត្តដែលផ្តល់ការគាំទ្រដល់ផ្នែកតម្រូវការ។ ក្រុមផ្តល់យោបល់ផ្នែកតម្រូវការ គឺជាក្រុមការងារកម្រិតបច្ចេកទេសដែលមានតួនាទីធ្វើទំនាក់ទំនងជាមួយបណ្តាញសម្រប សម្រួលគណនេយ្យភាពសហគមន៍ ក្នុងការជំរុញ ពង្រឹង និងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងផ្នែកតម្រូវការ ដោយសហការយ៉ាងជិតស្និទ្ធជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប.។

**សកម្មភាពជាអាទិភាព ១.១.៤ ៖ ពង្រឹងការអនុវត្តតួនាទី និងភារកិច្ចរបស់ក្រុមការងារគណនេយ្យភាពសង្គមរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ**

ដើម្បីសម្រេចបាននូវសកម្មភាពជាអាទិភាពខាងលើ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

– ពង្រឹងការអនុវត្តតួនាទី ភារកិច្ចក្រុមការងារ/មន្ត្រីបង្គោលនៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចជា ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គមដើម្បីដាក់បញ្ចូលទៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គណៈកម្មាធិការដឹកនាំការងារកំណែទម្រង់D&Dនៃក្រសួង ស្ថាប័នសាមី ការសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប.ក្នុងការរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត ឯកសារបច្ចេកទេស ផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ការផ្សព្វផ្សាយជូនប្រជាពលរដ្ឋ ការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងការគាំទ្របច្ចេកទេសដល់ការអនុវត្តការងារគណនេយ្យភាពសង្គមក្នុងក្របខណ្ឌនៃដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នសាមីនីមួយៗ។

**តារាងសូចនាករ និងចំណុចដៅសកម្មភាពជាអាទិភាពនៃលទ្ធផលរំពឹងទុក១.១**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |

**លទ្ធផលរំពឹងទុកទី ១.២ ៖** យន្តការដឹកនាំ សម្របសម្រួល និងគាំទ្រការងារគណនេយ្យភាពសង្គមនៅថ្នាក់រាជធានី ខេត្តត្រូវបានពង្រឹង និងធ្វើស្ថាប័នភាវូបនីយកម្ម ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងធានានិរន្តរភាពនៃការគាំទ្រ ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តគណនេយ្យភាពសង្គមរបស់រដ្ឋបាលមូលដ្ឋាន។

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទី១.២នេះ រួមមាន ៖

### សកម្មភាពជាអាទិភាព ១.២.១ ៖ ពង្រឹងការអនុវត្តតួនាទី ភារកិច្ចក្រុមការងារគណនេយ្យភាពសង្គមនៃរដ្ឋបាលរាជធានី ខេត្ត

ដើម្បីសម្រេចបាននូវសកម្មភាពជាអាទិភាពខាងលើ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- បន្តពង្រឹងការអនុវត្តតួនាទី ភារកិច្ចក្រុមការងារគណនេយ្យភាពសង្គមនៃរដ្ឋបាលរាជធានី ខេត្ត ដូចជា ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រុមការងារនេះដើម្បីដាក់បញ្ចូលក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់រាជធានី ខេត្ត ការគាំទ្របច្ចេកទេស ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងារគណនេយ្យភាពសង្គម រៀបចំកិច្ចប្រជុំត្រីមាសឱ្យបានទៀងទាត់ ការពង្រឹងកិច្ចសហការជាមួយបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAF-Network) នៅថ្នាក់រាជធានី ខេត្ត
- សិក្សាលទ្ធភាពធ្វើសមាហរណកម្មតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមការងារគណនេយ្យភាពសង្គមនៃរដ្ឋបាលរាជធានី ខេត្តទៅក្នុងតួនាទី ភារកិច្ចរបស់គណៈកម្មាធិការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រដ្ឋបាលរាជធានី ខេត្ត ឬទៅក្នុងអង្គភាពពាក់ព័ន្ធនៃរដ្ឋបាលរាជធានី ខេត្ត (ការធ្វើស្ថាប័នភាវូបនីយកម្មក្រុមការងារគណនេយ្យភាពសង្គមក្នុងរដ្ឋបាលរាជធានី ខេត្ត)

### សកម្មភាពជាអាទិភាព ១.២.២ ៖ បង្កើត និងទទួលស្គាល់បណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នៅតាមរដ្ឋបាលរាជធានី ខេត្ត

ដើម្បីសម្រេចបាននូវសកម្មភាពជាអាទិភាពខាងលើ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- រៀបចំឱ្យមានការទទួលស្គាល់ជាផ្លូវការដោយរដ្ឋបាលរាជធានី ខេត្តនូវបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នៅតាមរដ្ឋបាលរាជធានី ខេត្តសាមីនីមួយៗ ដើម្បីផ្តល់ភាពងាយស្រួលឱ្យបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ក្នុងការអនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព។ ក្នុងការរៀបចំឱ្យមានការ

ទទួលស្គាល់ជាផ្លូវការនូវបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នេះ ចាំបាច់ត្រូវមានការពិនិត្យ កែសម្រួល និងកំណត់ឱ្យបានច្បាស់លាស់នូវតួនាទី ភារកិច្ច ការទទួលខុសត្រូវ លក្ខខណ្ឌនៃការបង្កើតបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (ជាក្រុមអ្នកស្ម័គ្រចិត្ត)

- កំណត់នីតិវិធីផ្តល់ថវិកាឧបត្ថម្ភគាំទ្រដល់បណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដូចជា ការផ្តល់ប្រាក់បេសកកម្មសម្រាប់ការចូលរួមវគ្គបណ្តុះបណ្តាល សម្រាប់ការសម្របសម្រួលកិច្ចប្រជុំនានា និងគាំទ្របច្ចេកទេសដល់ CAF ថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។
- សិក្សា និងកំណត់ជម្រើសសមស្របសម្រាប់ការរៀបចំយន្តការគាំទ្រ និងលើកកម្ពស់និរន្តរភាពរបស់បណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAF-Network) នៅតាមរដ្ឋបាលរាជធានី ខេត្ត ដោយរក្សាឱ្យបាននូវលក្ខណៈជាក្រុមអ្នកស្ម័គ្រចិត្ត ភាពអព្យាក្រឹត្យ និងភាពជាតំណាងផ្នែកតម្រូវការ ព្រមទាំងរៀបចំយន្តការឧបត្ថម្ភ គាំទ្រ អភិវឌ្ឍសមត្ថភាព និងCAF-Network អាចបំពេញតួនាទី និងភារកិច្ចក្នុងការគាំទ្រដល់ផ្នែកតម្រូវការនៃការងារគណនេយ្យភាពសង្គមនៅតាមរដ្ឋបាលមូលដ្ឋាន។

**តារាងសូចនាករ និងចំណុចដៅសកម្មភាពជាអាទិភាពនៃលទ្ធផលរំពឹងទុក១.២**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

**លទ្ធផលរំពឹងទុកទី ១.៣ ៖** ប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់ការតាមដាន ត្រួតពិនិត្យ វាយតម្លៃការ និងប្រព័ន្ធឌីជីថលសម្រាប់ផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គមត្រូវបានធ្វើបច្ចុប្បន្នភាព កែលម្អ និងដាក់ឱ្យដំណើរការប្រកបដោយប្រសិទ្ធភាព។

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទី១.៣នេះ រួមមាន ៖

**សកម្មភាពជាអាទិភាព ១.៣.១ ៖ លើកកម្ពស់ការគ្រប់គ្រងប្រព័ន្ធទិន្នន័យសម្រាប់ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃការងារគណនេយ្យភាពសង្គម ប្រកបដោយប្រសិទ្ធភាព**

ដើម្បីសម្រេចបាននូវសកម្មភាពជាអាទិភាពខាងលើ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- ពិនិត្យ ធ្វើបច្ចុប្បន្នភាព និងកែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃការងារគណនេយ្យភាពសង្គម ដើម្បីធានាដល់ការប្រមូលទិន្នន័យពាក់ព័ន្ធនានាទាំងផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់ឱ្យបានគ្រប់ជ្រុងជ្រោយ
- ពិនិត្យ ធ្វើបច្ចុប្បន្នភាព និងជំរុញការប្រើប្រាស់ប្រព័ន្ធឌីជីថល (Applications) សម្រាប់ការផ្សព្វផ្សាយព័ត៌មាន និងការផ្តល់យោបល់នានាលើការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលមូលដ្ឋាន
- រៀបចំឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃការងារគណនេយ្យភាពសង្គមក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- បណ្តុះបណ្តាលអំពីប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃការងារគណនេយ្យភាពសង្គមដល់មន្ត្រីពាក់ព័ន្ធនៃរដ្ឋបាលថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- គាំទ្របច្ចេកទេស ការតាមដាន ត្រួតពិនិត្យលើការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃការងារគណនេយ្យភាពសង្គមរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- រៀបចំរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម ដើម្បីដាក់បញ្ចូលរបាយការណ៍នេះទៅក្នុងរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំរបស់ គ.ជ.អ.ប.
- រៀបចំការវាយតម្លៃពាក់កណ្តាលអាណត្តិ និងការវាយតម្លៃចុងបញ្ចប់នៃការអនុវត្ត ISAF-III។

**តារាងសូចនាករ និងចំណុចដៅសកម្មភាពជាអាទិភាពនៃលទ្ធផលរំពឹងទុក១.៣**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| | | | | | | | |
| | | | | | | | |

**លទ្ធផលរំពឹងទុកទី១.៤** ៖ កិច្ចសហការក្នុងភាពជាដៃគូរវាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ចជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋានត្រូវបានពង្រឹង ដើម្បីកៀរគរ និងប្រើប្រាស់ធនធាន ជំនាញ និងការចូលរួមគាំទ្រដល់ការអនុវត្តគណនេយ្យភាពសង្គមប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទី១.៤នេះ រួមមាន ៖

### សកម្មភាពជាអាទិភាព ១.៤.១. ៖ លើកកម្ពស់ភាពជាដៃគូក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម

ដើម្បីសម្រេចបាននូវសកម្មភាពជាអាទិភាពខាងលើ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- រៀបចំការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងសាធារណជនអំពីសារៈសំខាន់នៃគណនេយ្យភាពសង្គម (សមិទ្ធផលសំខាន់ៗដែលបានសម្រេច ទិសដៅ និងកិច្ចការជាអាទិភាពដែលត្រូវបន្តអនុវត្ត....)
- ដាក់បញ្ចូលរបៀបវារៈពាក់ព័ន្ធនឹងគណនេយ្យភាពសង្គមទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំ TWG of D&D ដើម្បីផ្សព្វផ្សាយ និងកៀរគរការគាំទ្រដល់ការងារគណនេយ្យភាពសង្គម
- រៀបចំវេទិកាឆ្លុះបញ្ចាំង និងផ្សព្វផ្សាយការអនុវត្តការងារគណនេយ្យភាពសង្គម
- បន្តពង្រឹងកិច្ចសហការ និងការពិភាក្សាជាមួយដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលក្នុងការដាក់បញ្ចូលសកម្មភាពជាអាទិភាពនៃ ISAF-III ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍប្រទេស កម្មវិធីនិងគម្រោងរបស់ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលដែលគាំទ្រដល់ការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

**តារាងសូចនាករ និងចំណុចដៅសកម្មភាពជាអាទិភាពនៃលទ្ធផលរំពឹងទុក១.៤**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| | | | | | | | |
| | | | | | | | |

## សមាសភាគទី២៖ យន្តការអនុវត្តគណនេយ្យភាពសង្គមរបស់រដ្ឋបាលមូលដ្ឋាន

### សន្និទានភាព

ការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិក្នុងដំណាក់កាលកន្លងមក បានបង្ហាញថា ការចូលរួមរបស់ប្រជាពលរដ្ឋ និងការឆ្លើយតបរបស់រដ្ឋបាលមូលដ្ឋាន គឺជាកត្តាសំខាន់ក្នុងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។ ទន្ទឹមនឹងនេះ ការធានាឱ្យការងារគណនេយ្យភាពសង្គមអាចបន្តអនុវត្តបានប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព មិនអាចពឹងផ្អែកតែលើយន្តការគាំទ្រពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលតែមួយមុខនោះទេ ប៉ុន្តែត្រូវផ្អែកជាចម្បងលើ ភាពម្ចាស់ការ ការទទួលខុសត្រូវ និងសមត្ថភាពរបស់រដ្ឋបាលមូលដ្ឋាននីមួយៗ ក្នុងការរៀបចំគ្រប់គ្រង និងអនុវត្តការងារគណនេយ្យភាពសង្គមក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្នុងបរិបទនេះ ចាំបាច់ត្រូវពង្រឹងយន្តការគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់ ឱ្យមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវកាន់តែច្បាស់លាស់ ព្រមទាំងមានការរៀបចំយន្តការគាំទ្រដែលអាចបន្តដំណើរការបានជាប្រចាំ និងមាននិរន្តរភាព។ ការពង្រឹងយន្តការនៅរដ្ឋបាលទាំងពីរកម្រិតនេះ នឹងជួយឱ្យការងារគណនេយ្យភាពសង្គមក្លាយជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រងការងាររបស់រដ្ឋបាលមូលដ្ឋាន ជាជាងជាសកម្មភាពដាច់ដោយឡែកដែលពឹងផ្អែកលើគម្រោង ឬកម្មវិធីរបស់ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល។

នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវមានយន្តការដែលមានសមត្ថភាពក្នុងការដឹកនាំ សម្របសម្រួល គាំទ្រ និងត្រួតពិនិត្យការអនុវត្តការងារគណនេយ្យភាពសង្គមនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជាពិសេសការសម្របសម្រួលរវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ រដ្ឋបាលឃុំ សង្កាត់ អង្គភាពផ្តល់សេវា និងប្រជាពលរដ្ឋ។ ដូច្នេះ ការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ក្រុមការងារគណនេយ្យភាពសង្គម និងការសិក្សាជម្រើសនានាសម្រាប់ធ្វើឱ្យតួនាទីទាំងនេះក្លាយជាផ្នែកមួយនៃរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងការងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ គឺមានសារៈសំខាន់ចំពោះការធានានិរន្តរភាព។

ជាមួយគ្នានេះ ក្នុងផ្នែកតម្រូវការក៏ត្រូវការអ្នកសម្របសម្រួលដែលអាចពាំនាំសំឡេង តម្រូវការ និងមតិយោបល់របស់ប្រជាពលរដ្ឋជូនទៅរដ្ឋបាលមូលដ្ឋាន និងអង្គភាពផ្តល់សេវាផងដែរ។ ដូច្នេះ ការពង្រឹង CAF និង CAF-Network គឺជាផ្នែកសំខាន់មួយនៃសមាសភាគនេះ។ ទោះជាយ៉ាងណា ដើម្បីរក្សាភាពជឿទុកចិត្ត និងប្រសិទ្ធភាពនៃផ្នែកតម្រូវការ CAF និង CAF-Network ត្រូវរក្សាក្នុងលក្ខណៈជាអ្នកស្ម័គ្រចិត្តដែលមានអព្យាក្រឹតភាព និងជាតំណាងផ្នែកតម្រូវការ។ ហេតុនេះ ការរៀបចំយន្តការទទួលស្គាល់ ការអភិវឌ្ឍសមត្ថភាព និងការឧបត្ថម្ភគាំទ្រដល់ CAF និង CAF-Network គួរផ្តោតលើការបង្កើតលក្ខខណ្ឌដែលមិនធ្វើឱ្យប៉ះពាល់ដល់អព្យាក្រឹតភាពរបស់ CAF និង CAF-Networkឡើយ។

នៅថ្នាក់ឃុំ សង្កាត់ ការពង្រឹងយន្តការ JAAP និងការសម្របសម្រួលរវាងរដ្ឋបាលឃុំ សង្កាត់ អង្គភាពផ្តល់សេវា និងប្រជាពលរដ្ឋ មានសារៈសំខាន់សម្រាប់ធានាឱ្យព័ត៌មានអំពីស្តង់ដា គុណភាពសេវា តម្រូវការ និងមតិយោបល់របស់ប្រជាពលរដ្ឋ ត្រូវបានប្រមូល និងប្រើប្រាស់ក្នុងដំណើរការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។ ដូច្នេះ ការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការ JAAP ព្រមទាំងការសិក្សា

ជម្រើសសម្រាប់ធ្វើសមាហរណកម្មយន្តការនេះទៅក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលឃុំ សង្កាត់ នឹងជួយកាត់បន្ថយការពឹងផ្អែកលើយន្តការដែលបង្កើតឡើងដោយគម្រោង និងបង្កើននិរន្តរភាពនៃការអនុវត្តការងារគណនេយ្យភាពសង្គម។

ម្យ៉ាងទៀត ការអនុវត្តការងារគណនេយ្យភាពសង្គមនៅកម្រិតមូលដ្ឋាន ត្រូវការប្រព័ន្ធទិន្នន័យដែលអាចផ្តល់ព័ត៌មានទាន់ពេលវេលា អាចប្រើប្រាស់សម្រាប់ការតាមដាន និងវាយតម្លៃ និងគាំទ្រដល់ការសម្រេចចិត្តរបស់រដ្ឋបាលមូលដ្ឋាន។ ដូច្នេះ ការរៀបចំ និងដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងទិន្នន័យគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ នឹងជួយពង្រឹងការគ្រប់គ្រងទិន្នន័យ បង្កើនតម្លាភាព និងធ្វើឱ្យការតាមដាន និងវាយតម្លៃគណនេយ្យភាពសង្គមមានប្រសិទ្ធភាពជាងមុន។

អាស្រ័យហេតុនេះ សមាសភាគទី២ នេះត្រូវបានរៀបចំឡើង ដើម្បីផ្លាស់ប្តូរទិសដៅពីការអនុវត្តដែលពឹងផ្អែកលើយន្តការគាំទ្រពីខាងក្រៅ ទៅរកការអនុវត្តដែលមានភាពម្ចាស់ការ និងការទទួលខុសត្រូវកាន់តែខ្ពស់របស់រដ្ឋបាលមូលដ្ឋាន ព្រមទាំងបង្កើតលក្ខខណ្ឌសម្រាប់ការបន្តអនុវត្តគណនេយ្យភាពសង្គមប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

**សមិទ្ធផលរំពឹងទុក៖**

ភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌក្នុងការរៀបចំ និងអនុវត្តគណនេយ្យភាពសង្គមត្រូវបានពង្រឹង និងធ្វើស្ថាប័នការូបនីយកម្ម ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងធានានិរន្តរភាពនៃការអនុវត្តគណនេយ្យភាពសង្គមក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលនីមួយៗ។

ដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកខាងលើ សមាសភាគទី២បានកំណត់នូវលទ្ធផលរំពឹងទុកចំនួន០២ រួមមាន ៖

**លទ្ធផលរំពឹងទុកទី ២.១ ៖**

យន្តការអនុវត្តការងារគណនេយ្យភាពសង្គមរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានពង្រឹង និងធ្វើស្ថាប័នការូបនីយកម្ម ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងធានានិរន្តរភាពការអនុវត្តគណនេយ្យភាពសង្គមក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ។

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទី២.១នេះ រួមមាន ៖

### សកម្មភាពជាអាទិភាព ២.១.១ ៖ ពង្រឹង និងសមាហរណកម្មក្រុមការងារគណនេយ្យភាពសង្គមនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌ

ដើម្បីសម្រេចបាននូវសកម្មភាពជាអាទិភាពខាងលើ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- ពង្រឹងការអនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់គណៈកម្មាធិការគណនេយ្យភាពសង្គមរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- សិក្សាលទ្ធភាពធ្វើសមាហរណកម្មតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមការងារគណនេយ្យភាពសង្គមនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌទៅក្នុងគណៈកម្មាធិការដឹកនាំការងារ

សេចក្តីព្រាង ១

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រុង ស្រុក ខណ្ឌ ឬទៅក្នុងអង្គភាពពាក់ព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ (ការធ្វើស្ថាប័នភាវូបនីយកម្មក្រុមការងារគណនេយ្យភាពសង្គមក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌ)

**សកម្មភាពជាអាទិភាព ២.១.២ ៖ បង្កើត និងទទួលស្គាល់បណ្តាញអ្នកសម្របសម្រួលសហគមន៍នៅថ្នាក់ក្រុង ស្រុក ខណ្ឌ**

ដើម្បីសម្រេចបាននូវសកម្មភាពជាអាទិភាពខាងលើ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- ពង្រឹងការអនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងបណ្តាញអ្នកសម្របសម្រួលសហគមន៍នៅថ្នាក់ក្រុង ស្រុក ខណ្ឌ (CAF and CAF network)
- រៀបចំឱ្យមានការទទួលស្គាល់ជាផ្លូវការនូវអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ជាក្រុមស្ម័គ្រចិត្តជួយសហគមន៍នៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌសាមីនីមួយៗ ដើម្បីបង្កលក្ខណៈ ងាយស្រួលឱ្យអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍អនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព។ ក្នុងការរៀបចំឱ្យមានការទទួលស្គាល់ជាផ្លូវការនូវអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នេះចាំបាច់ត្រូវមានការពិនិត្យកែសម្រួល និងកំណត់ឱ្យបានច្បាស់លាស់នូវតួនាទី ភារកិច្ច ការទទួលខុសត្រូវ លក្ខខណ្ឌនៃការបង្កើតអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (ជាអ្នកស្ម័គ្រចិត្ត)
- កំណត់នីតិវិធីផ្តល់ថវិកាឧបត្ថម្ភគាំទ្រដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដូចជាការផ្តល់ប្រាក់បេសកកម្ម សម្រាប់ការចូលរួមវគ្គបណ្តុះបណ្តាល និងសម្រាប់ការសម្របសម្រួលកិច្ចប្រជុំនានាជាដើម។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នៅថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវមានតួនាទីជាបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដែលត្រូវមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នៅតាមរដ្ឋបាលឃុំ សង្កាត់។

**សកម្មភាពជាអាទិភាព២.១.៣ ៖ រៀបចំយន្តការគាំទ្រ និងលើកកម្ពស់និរន្តរភាពរបស់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍**

ដើម្បីសម្រេចបាននូវសកម្មភាពជាអាទិភាពខាងលើ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- សិក្សា និងកំណត់ជម្រើសសមស្របសម្រាប់ការរៀបចំយន្តការគាំទ្រ និងលើកកម្ពស់និរន្តរភាពរបស់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAF) និងបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAF-Network) នៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយរក្សាឱ្យបាននូវលក្ខណៈជាក្រុមអ្នកស្ម័គ្រចិត្ត ភាពអព្យាក្រឹត្យ និងភាពជាតំណាងផ្នែកតម្រូវការ ព្រមទាំងរៀបចំយន្តការឧបត្ថម្ភ គាំទ្រ អភិវឌ្ឍសមត្ថភាព និងសម្របសម្រួលសម

ស្រប ដើម្បីធានាឱ្យ CAF និង CAF-Network អាចបន្តបំពេញតួនាទី និងភារកិច្ចក្នុងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងគាំទ្រដំណើរការគណនេយ្យភាពសង្គមនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

**សកម្មភាពជាអាទិភាព២.១.៤ ៖ ការគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងទិន្នន័យគណនេយ្យភាពសង្គម**

- សកម្មភាពនេះផ្តោតលើគ្រប់គ្រង និងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការងារគណនេយ្យភាពសង្គម និងប្រព័ន្ធឌីជីថលផ្សេងៗទៀតពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌនិងឃុំ សង្កាត់សាមីនីមួយៗ

**តារាងសូចនាករ និងចំណុចដៅសកម្មភាពជាអាទិភាពនៃលទ្ធផលរំពឹងទុក២.១**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

**លទ្ធផលរំពឹងទុកទី ២.២ ៖**

យន្តការអនុវត្តការងារគណនេយ្យភាពសង្គមរបស់រដ្ឋបាលឃុំ សង្កាត់ត្រូវបានពង្រឹង និងធ្វើស្ថាប័នភាវូបនីយកម្ម ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងធានានិរន្តរភាពការងារគណនេយ្យភាពសង្គក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗ។

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទី២.២នេះ រួមមាន ៖

**សកម្មភាពជាអាទិភាព២.២.១៖ លើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញតួនាទីរបស់គណៈកម្មាធិការ JAAP**

ដើម្បីសម្រេចបាននូវសកម្មភាពជាអាទិភាពខាងលើ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- ពង្រឹងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មាធិការ JAAP ដោយរដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាពលើការងារគណនេយ្យភាពសង្គម
- សិក្សាលទ្ធភាពក្នុងការធ្វើសមាហរណកម្មគណៈកម្មាធិការ JAAP ទៅក្នុងគណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ ឬគណៈកម្មាធិការពាក់ព័ន្ធផ្សេងទៀតរបស់រដ្ឋបាលឃុំ សង្កាត់សាមីនីមួយៗ

**សកម្មភាពជាអាទិភាព ២.២.២ ៖ លើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញការងាររបស់ CAF**

ដើម្បីសម្រេចបាននូវសកម្មភាពជាអាទិភាពខាងលើ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- ពង្រឹងការអនុវត្តតួនាទីរបស់អ្នកសម្របសម្រួលសហគមន៍នៅថ្នាក់ឃុំ សង្កាត់ (CAF)

- រៀបចំឱ្យមានការទទួលស្គាល់ជាផ្លូវការដោយរដ្ឋបាលឃុំ សង្កាត់នូវអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នៅតាមរដ្ឋបាលឃុំ សង្កាត់សាមីនីមួយៗ ដើម្បីបង្កលក្ខណៈងាយស្រួលឱ្យអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍អនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព។ ក្នុងការរៀបចំឱ្យមានការទទួលស្គាល់ជាផ្លូវការនូវអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នេះចាំបាច់ត្រូវមានការពិនិត្យ កែសម្រួល និងកំណត់ឱ្យបានច្បាស់លាស់នូវតួនាទី ភារកិច្ច ការទទួលខុសត្រូវ លក្ខខណ្ឌជ្រើសរើស/ការបង្កើតអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (ជាអ្នកស្ម័គ្រចិត្ត)
- កំណត់នីតិវិធី ផ្តល់ថវិកាឧបត្ថម្ភគាំទ្រដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដូចជា ប្រាក់បេសកកម្មសម្រាប់ការចូលរួមវគ្គបណ្តុះបណ្តាល និងសម្រាប់ការសម្របសម្រួលកិច្ចប្រជុំនានា។

### សកម្មភាពជាអាទិភាព២.២.៣ ៖ ការគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងទិន្នន័យគណនេយ្យភាពសង្គម

- សកម្មភាពនេះផ្តោតលើការគ្រប់គ្រង និងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារគណនេយ្យភាពសង្គម និងប្រព័ន្ធឌីជីថលផ្សេងៗទៀតពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់សាមីនីមួយៗ

**តារាងសូចនាករ និងចំណុចដៅសកម្មភាពជាអាទិភាពនៃលទ្ធផលរំពឹងទុក២.២**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

## សមាសភាគទី ៣ ÷ ការអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គម

### សនិទានភាព

ការអភិវឌ្ឍសមត្ថភាព គឺជាមូលដ្ឋានសំខាន់សម្រាប់ធានាឱ្យការងារគណនេយ្យភាពសង្គមអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។ បទពិសោធន៍នៃការអនុវត្តការងារគណនេយ្យភាពសង្គមកន្លងមក បានបង្ហាញថា ការយល់ដឹង ចំណេះដឹង និងជំនាញរបស់អ្នកពាក់ព័ន្ធទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ គឺជាកត្តាសំខាន់ក្នុងការលើកកម្ពស់គុណភាពនៃការអនុវត្តគណនេយ្យភាពសង្គម ទាំងក្នុងការផ្សព្វផ្សាយ និងប្រើប្រាស់ព័ត៌មាន និងការចូលរួមមតិយោបល់របស់ប្រជាពលរដ្ឋ ដើម្បីកែលម្អការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

ក្នុងក្របខណ្ឌ ISAF-III បានផ្តោតកាន់តែខ្លាំងទៅលើការលើកកម្ពស់ភាពម្ចាស់ការ ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអភិវឌ្ឍសមត្ថភាពគណនេយ្យភាពសង្គមដល់រដ្ឋបាលថ្នាក់មូលដ្ឋាន និងភាគីពាក់ព័ន្ធនានា។ ក្នុងន័យនេះ ការពង្រឹងតួនាទីរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA) និងយន្តការអភិវឌ្ឍសមត្ថភាពរបស់រាជធានី ខេត្ត គឺជាមូលដ្ឋានសំខាន់សម្រាប់ធានាឱ្យការអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គមអាចបន្តអនុវត្តបានប្រកបដោយនិរន្តរភាព។

ជាទូទៅ តម្រូវការអភិវឌ្ឍសមត្ថភាពរបស់អ្នកពាក់ព័ន្ធមិនមានលក្ខណៈដូចគ្នានោះទេ។ ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវការចំណេះដឹង និងជំនាញសម្រាប់រៀបចំ និងអនុវត្តដំណើរការគណនេយ្យភាពសង្គមផ្នែកផ្គត់ផ្គង់ ដូចជា បញ្ចូលព័ត៌មាន និងមតិយោបល់របស់ប្រជាពលរដ្ឋទៅក្នុងការរៀបចំផែនការ និងការកែលម្អការផ្តល់សេវា។ អង្គភាពផ្តល់សេវា និងអ្នកពាក់ព័ន្ធផ្សេងទៀត ត្រូវការសមត្ថភាពក្នុងការប្រើប្រាស់ព័ត៌មានពីប្រជាពលរដ្ឋ និងឆ្លើយតបចំពោះតម្រូវការ និងបញ្ហាប្រឈមដែលបានលើកឡើង។ ចំណែកឯ CAF និងសហគមន៍មូលដ្ឋាន ត្រូវការសមត្ថភាពក្នុងការផ្សព្វផ្សាយព័ត៌មាន ជំរុញការចូលរួម ប្រមូលមតិយោបល់ និងសម្របសម្រួលការបញ្ជូនបញ្ហាប្រឈម និងតម្រូវការរបស់ប្រជាពលរដ្ឋទៅកាន់រដ្ឋបាលមូលដ្ឋាន និងអង្គភាពផ្តល់សេវា។

ដោយហេតុនេះ ការអភិវឌ្ឍសមត្ថភាពក្នុង ISAF-III មិនត្រូវផ្តោតតែលើការរៀបចំវគ្គបណ្តុះបណ្តាលជាលក្ខណៈផ្លូវការប៉ុណ្ណោះទេ ប៉ុន្តែត្រូវរួមបញ្ចូលវិធីសាស្ត្រជាច្រើន ដូចជា ការបណ្តុះបណ្តាលជាក់ស្តែង ការគាំទ្របច្ចេកទេសនៅនឹងកន្លែង ការរៀនសូត្រពីគ្នាទៅវិញទៅមក ការរៀនតាមប្រព័ន្ធអនឡាញ ការចែករំលែកបទពិសោធន៍ និងការអនុវត្តជាក់ស្តែង។ ជាពិសេស ត្រូវមានការតាមដាន និងវាយតម្លៃថា តើការអភិវឌ្ឍសមត្ថភាពបាននាំឱ្យមានការផ្លាស់ប្តូរចំណេះដឹង ជំនាញ និងការអនុវត្តការងាររបស់អ្នកពាក់ព័ន្ធយ៉ាងដូចម្តេច។

អាស្រ័យហេតុនេះ សមាសភាគទី៣ ត្រូវបានរៀបចំឡើងដើម្បីពង្រឹងទាំងប្រព័ន្ធ យន្តការ និងសមត្ថភាពជាក់ស្តែងរបស់អ្នកពាក់ព័ន្ធក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម។ តាមរយៈការរៀបចំផែនការអភិវឌ្ឍសមត្ថភាពផ្អែកលើតម្រូវការជាក់ស្តែង ការពង្រឹងស្ថាប័នដឹកនាំ និងសម្របសម្រួល ការធ្វើសមាហរណកម្មការអភិវឌ្ឍសមត្ថភាពទៅក្នុងប្រព័ន្ធដែលមានស្រាប់ និងការពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សា បុគ្គលិករបស់រដ្ឋបាលមូលដ្ឋាន CAF និងសហគមន៍មូលដ្ឋាន នឹងជួយបង្កើតមូលដ្ឋានរឹងមាំសម្រាប់

ការអនុវត្តការងារគណនេយ្យភាពសង្គមប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ទាំងក្នុងអំឡុងពេលអនុវត្ត ISAF-III និងក្រោយពេលបញ្ចប់ផែនការនេះ។

**សមិទ្ធផលរំពឹងទុក ៖**

ប្រព័ន្ធ និងយន្តការអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គមត្រូវបានពង្រឹង និងធានានិរន្តរភាព ដើម្បីលើកកម្ពស់ចំណេះដឹង ជំនាញ និងសមត្ថភាពរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋក្នុងការអនុវត្តគណនេយ្យភាពសង្គម។

ដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកខាងលើ សមាសភាគទី៣បានកំណត់នូវលទ្ធផលរំពឹងទុកចំនួន០៣ រួមមាន ៖

**លទ្ធផលរំពឹងទុកទី៣.១ ៖**

យន្តការអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គមត្រូវបានពង្រឹង និងធ្វើស្ថាប័នភាវូបនីយកម្ម ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍសមត្ថភាពរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា។

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទី៣.១នេះ រួមមាន ៖

**សកម្មភាពជាអាទិភាព ៣.១.១. ៖ ពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នដឹកនាំ និងសម្របសម្រួលការអភិវឌ្ឍសមត្ថភាពនៅថ្នាក់ជាតិ**

ដើម្បីសម្រេចបាននូវសកម្មភាពជាអាទិភាពខាងលើ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- បន្តពង្រឹងតួនាទីរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការដឹកនាំ សម្របសម្រួល និងផ្តល់ការគាំទ្របច្ចេកទេសលើការអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គម។
- ផ្ទេរការទទួលខុសត្រូវជាបណ្តើរៗទៅឱ្យ NASLA ដើរតួនាទីជាស្ថាប័នដឹកនាំ និងសម្របសម្រួលការអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គម
- គាំទ្រ NASLA ក្នុងការរៀបចំ និងដាក់បញ្ចូលប្រធានបទពាក់ព័ន្ធនឹងគណនេយ្យភាពសង្គមទៅក្នុងកម្មវិធីសិក្សា និងកម្មវិធីអភិវឌ្ឍសមត្ថភាពជាផ្លូវការ
- រៀបចំ និងកំណត់តួនាទីរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានាក្នុងការរួមចំណែកដល់ការអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គម។

**សកម្មភាពជាអាទិភាព ៣.១.២. ៖ ពង្រឹងយន្តការអភិវឌ្ឍសមត្ថភាពនៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- ពង្រឹងក្រុមគ្រូបង្គោល និងយន្តការផ្តល់សេវាអភិវឌ្ឍសមត្ថភាពដែលមានស្រាប់នៅថ្នាក់រាជធានី ខេត្ត

- ពង្រឹងទីចាត់ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលរាជធានី ខេត្ត ឱ្យមានតួនាទីសម្របសម្រួលការអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គម
- រៀបចំឱ្យមានយន្តការសហការរវាងរដ្ឋបាលរាជធានី ខេត្ត មន្ទីរ/អង្គភាពពាក់ព័ន្ធ បណ្តាញ CAF និងអង្គការដៃគូ ក្នុងការផ្តល់សេវាអភិវឌ្ឍសមត្ថភាព។

**សកម្មភាពជាអាទិភាព ៣.១.៣៖ ពង្រឹងតួនាទីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការគាំទ្រ និងអភិវឌ្ឍសមត្ថភាពរដ្ឋបាលឃុំ សង្កាត់អំពីការងារគណនេយ្យភាពសង្គម។**

កិច្ចការសំខាន់ៗអាចរួមមាន៖

- រៀបចំផែនការអភិវឌ្ឍសមត្ថភាពស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់រដ្ឋបាលឃុំ សង្កាត់ ដោយផ្អែកលើតម្រូវការជាក់ស្តែង។
- ផ្តល់ការបណ្តុះបណ្តាល ការណែនាំ និងការបង្ហាត់បង្រៀនលើការអនុវត្តកាងារជាក់ស្តែង (on-the-job coaching ដល់រដ្ឋបាលឃុំ សង្កាត់។
- ជួយគាំទ្រឃុំ សង្កាត់អនុវត្ត JAAP, ការប្រមូល មតិយោបល់របស់ប្រជាពលរដ្ឋ, ការផ្សព្វផ្សាយ I4Cs និងការប្រើប្រាស់ប្រព័ន្ធទិន្នន័យគណនេយ្យភាពសង្គម។
- រៀបចំការរៀនសូត្រពីគ្នារវាងឃុំ សង្កាត់ក្នុងក្រុង ស្រុក ខណ្ឌ។
- តាមដាន ត្រួតពិនិត្យ និងគាំទ្របច្ចេកទេសដល់ឃុំ សង្កាត់តាមតម្រូវការចាំបាច់។

**តារាងសូចនាករ និងចំណុចដៅសកម្មភាពជាអាទិភាពនៃលទ្ធផលរំពឹងទុក៣.១**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

**លទ្ធផលរំពឹងទុកទី ៣.២** ៖ ផែនការអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គមត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាប្រចាំស្របតាមតម្រូវការរបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា។

ផែនការ និងកម្មវិធីអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គមត្រូវបានរៀបចំ និងអនុវត្តជាប្រចាំ ស្របតាមតម្រូវការរបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា។

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទី៣.២នេះ រួមមាន ៖

**សកម្មភាពជាអាទិភាព ៣.២.១ ៖ វាយតម្លៃតម្រូវការ និងរៀបចំផែនការអភិវឌ្ឍសមត្ថភាព**

ដើម្បីសម្រេចបាននូវសកម្មភាពជាអាទិភាពខាងលើ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- រៀបចំការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព (TNA) ជាប្រចាំ។
- រៀបចំផែនការអភិវឌ្ឍសមត្ថភាពដោយផ្អែកលើលទ្ធផល TNA និងកំណត់ក្រុមគោលដៅ ប្រធានបទ វិធីសាស្ត្រ រយៈពេល និងអ្នកទទួលខុសត្រូវ។
- ធ្វើបច្ចុប្បន្នភាពផែនការអភិវឌ្ឍសមត្ថភាពឱ្យស្របតាមការវិវត្តនៃការអនុវត្តគណនេយ្យភាពសង្គម។

**សកម្មភាពជាអាទិភាព ៣.២.២ ៖ រៀបចំ និងធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា និងសម្ភារៈអភិវឌ្ឍសមត្ថភាព**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- រៀបចំកម្មវិធីសិក្សាតាមប្រធានបទ និងក្រុមគោលដៅដែលបានកំណត់ក្នុងផែនការ។
- រៀបចំ និងធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំ ឯកសារបណ្តុះបណ្តាល ឧបករណ៍ និងសម្ភារៈសិក្សាពាក់ព័ន្ធ។
- បញ្ចូលមេរៀន និងបទពិសោធន៍ពីការអនុវត្តជាក់ស្តែងទៅក្នុងកម្មវិធីសិក្សា។

**សកម្មភាពជាអាទិភាព ៣.២.៣ ៖ អនុវត្តផែនការ និងកម្មវិធីអភិវឌ្ឍសមត្ថភាព**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- ក្នុងអំឡុងពេលដែលសាលាជាតិរដ្ឋបាលមូលដ្ឋានពុំទាន់មានសមត្ថភាព និងលទ្ធភាពពេញលេញ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបន្តកិច្ចសហការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលលើការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គម
- ទន្ទឹមគ្នានេះក៏ត្រូវពង្រឹងការទទួលខុសត្រូវរបស់ NASLA ជាបណ្តើរៗ ក្នុងការដឹកនាំ សម្របសម្រួលការអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គម។ ផ្អែកលើកម្មវិធីសិក្សាតាមប្រធានបទនីមួយៗ ការបណ្តុះបណ្តាលអំពីការងារគណនេយ្យភាពសង្គមអាចត្រូវបានរៀបចំដោយក្រសួង ស្ថាប័ន គ្រឹះស្ថានសិក្សា អង្គភាពសង្គមស៊ីវិល ផ្នែកឯកជន ក្រោមការសម្របសម្រួល និងត្រួតពិនិត្យរបស់ NASLA (contracting out)
- រៀបចំវគ្គបណ្តុះបណ្តាលផ្លូវការ (រៀបចំវគ្គបណ្តុះបណ្តាលកគណនេយ្យភាពសង្គមដល់រដ្ឋបាលមូលដ្ឋាន និងCAFs.)

**សកម្មភាពជាអាទិភាព ៣.២.៤៖ ធ្វើសមាហរណកម្មការអភិវឌ្ឍសមត្ថភាពគណនេយ្យភាពសង្គមក្នុងប្រព័ន្ធអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- ពង្រឹងការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពស្តីពីគណនេយ្យភាពសង្គម ដោយក្រុមការងារគណនេយ្យភាពសង្គមថ្នាក់រាជធានី ខេត្ត

- ធ្វើសមាហរណកម្មការការអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គមទៅក្នុងផែនការអភិវឌ្ឍសមត្ថភាពរួមរបស់រាជធានី ខេត្ត
- ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំលើការអនុវត្តផែនការអភិវឌ្ឍសមត្ថភាពរបស់រាជធានី ខេត្ត រួមបញ្ចូលការត្រួតពិនិត្យ និងវាយតម្លៃលើការអភិវឌ្ឍសមត្ថភាពអំពីការងារគណនេយ្យភាពសង្គម

**សកម្មភាពជាអាទិភាព ៣.២.៥៖ជំរុញការរៀនសូត្រពីគ្នាទៅវិញទៅមក និងការចែករំលែកបទពិសោធន៍**

- អភិវឌ្ឍ និងប្រើប្រាស់ការរៀនតាមប្រព័ន្ធឌីជីថល និងអនឡាញ។
- រៀបចំការចងក្រង និងផ្សព្វផ្សាយមេរៀន បទពិសោធន៍ និងការអនុវត្តល្អ
- រៀបចំប្រព័ន្ធគាំទ្របច្ចេកទេស និងការរៀនសូត្របន្តបន្ទាប់ក្រោយពេលបណ្តុះបណ្តាល
- ជំរុញ និងពង្រឹងការរៀបចំ និងអនុវត្តការរៀនសូត្រពីគ្នាទៅវិញទៅមក
- រៀបចំការចងក្រង និងចែករំលែកបទពិសោធន៍អំពីការអនុវត្តការងារគណនេយ្យភាពសង្គម

**តារាងសូចនាករ និងចំណុចដៅសកម្មភាពជាអាទិភាពនៃលទ្ធផលរំពឹងទុក៣.២**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

**លទ្ធផលរំពឹងទុកទី ៣.៣៖** សមត្ថភាពរបស់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងអ្នកពាក់ព័ន្ធ និងសហគមន៍មូលដ្ឋានក្នុងការអនុវត្តគណនេយ្យភាពសង្គមត្រូវបានពង្រឹង។

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទី៣.២នេះ រួមមាន ៖

**សកម្មភាពជាអាទិភាព ៣.៣.១៖ ពង្រឹងចំណេះដឹង និងជំនាញរបស់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន៖

- រៀបចំ និងអនុវត្តវគ្គបណ្តុះបណ្តាល និងកម្មវិធីអភិវឌ្ឍសមត្ថភាពអំពីគណនេយ្យភាពសង្គមដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ស្របតាមតម្រូវការដែលបានកំណត់ក្នុង TNA និងផែនការអភិវឌ្ឍសមត្ថភាព។
- ផ្តល់ការគាំទ្របច្ចេកទេស និងការណែនាំជាក់ស្តែងដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តឧបករណ៍ វិធីសាស្ត្រ និងដំណើរការគណនេយ្យភាពសង្គមក្នុងការងារប្រចាំថ្ងៃ
- ពង្រឹងសមត្ថភាពរដ្ឋបាលមូលដ្ឋានក្នុងការប្រើប្រាស់ព័ត៌មាន និងទិន្នន័យដែលទទួលបានពី

ការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការកែលម្អការរៀបចំផែនការ ការគ្រប់គ្រងធនធាន និងការផ្តល់សេវាសាធារណៈ

- រៀបចំ និងអនុវត្តការរៀនសូត្រពីគ្នាទៅវិញទៅមករវាងរដ្ឋបាលមូលដ្ឋាន ដើម្បីចែករំលែកបទពិសោធន៍ មេរៀន និងការអនុវត្តល្អក្នុងការងារគណនេយ្យភាពសង្គម។

**សកម្មភាពជាអាទិភាព ៣.៣.២៖ ពង្រឹងសមត្ថភាពរបស់ CAF និង CAF-Network ក្នុងការគាំទ្រផ្នែកតម្រូវការនៃការងារគណនេយ្យភាពសង្គម**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន៖

- ផ្តល់ការអភិវឌ្ឍសមត្ថភាពជាប្រចាំដល់ CAF និង CAF-Network អំពីតួនាទី ភារកិច្ច និងជំនាញសម្រាប់ការជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ និងការអនុវត្តការងារគណនេយ្យភាពសង្គម។
- ពង្រឹងសមត្ថភាពជំនាញរបស់ CAF ក្នុងការផ្សព្វផ្សាយព័ត៌មាន ប្រមូល និងចងក្រងមតិយោបល់ និងតម្រូវការរបស់ប្រជាពលរដ្ឋ សម្របសម្រួលការចូលរួមរបស់សហគមន៍ និងផ្សារភ្ជាប់មតិយោបល់ និងសំណើសំណូមពររបស់ប្រជាពលរដ្ឋជាមួយរដ្ឋបាលមូលដ្ឋាន និងអង្គភាពផ្តល់សេវា។
- ពង្រឹងសមត្ថភាព CAF-Network ក្នុងការសម្របសម្រួល ចែករំលែកព័ត៌មាន និងបទពិសោធន៍ ព្រមទាំងគាំទ្រ CAF នៅតាមឃុំ សង្កាត់។

**សកម្មភាពជាអាទិភាព ៣.៣.៣៖ ពង្រឹងសមត្ថភាពរបស់អង្គភាពផ្តល់សេវា**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន៖

- ពង្រឹងសមត្ថភាពរបស់អង្គភាពផ្តល់សេវាពាក់ព័ន្ធក្នុងការទទួល ប្រើប្រាស់ និងឆ្លើយតបចំពោះព័ត៌មាន មតិយោបល់ និងតម្រូវការរបស់ប្រជាពលរដ្ឋដែលទទួលបានតាមរយៈដំណើរការគណនេយ្យភាពសង្គម។
- គាំទ្របច្ចេកទេសដល់អង្គភាពផ្តល់សេវា ដើម្បីពង្រឹងការអនុវត្តវិធានការកែលម្អគុណភាពសេវាផ្អែកលើមតិយោបល់ និងទិន្នន័យពីប្រជាពលរដ្ឋ។
- ជំរុញការរៀនសូត្រ និងចែករំលែកបទពិសោធន៍រវាងអង្គភាពផ្តល់សេវា អំពីការឆ្លើយតបចំពោះតម្រូវការ និងមតិយោបល់របស់ប្រជាពលរដ្ឋ។

**សកម្មភាពជាអាទិភាព ៣.៣.៤៖ ពង្រឹងចំណេះដឹងរបស់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន៖

- ជំរុញការផ្សព្វផ្សាយ និងពង្រឹងការយល់ដឹងរបស់ប្រជាពលរដ្ឋ ជាពិសេសក្រុមជនងាយរងគ្រោះអំពីសិទ្ធិ តួនាទី និងឱកាសចូលរួមក្នុងដំណើរការគ្រប់គ្រង ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

សេចក្តីព្រាង ១

- ពង្រឹងចំណេះដឹងរបស់ប្រជាពលរដ្ឋអំពីព័ត៌មានសេវា ស្តង់ដាសេវា ថវិកា ផែនការ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតដែលចាំបាច់សម្រាប់ការចូលរួមក្នុងដំណើរការគណនេយ្យភាពសង្គម។
- ពង្រឹងចំណេះដឹង និងជំរុញការចូលរួមរបស់ស្ត្រី បុរស យុវជន និងក្រុមជនងាយរងគ្រោះក្នុងដំណើរការគណនេយ្យភាពសង្គម ដើម្បីធានាឱ្យមានបរិយាបន្ន និងសមធម៌សង្គម។

### សកម្មភាពជាអាទិភាព ៣.៣.៥៖ តាមដាន និងវាយតម្លៃលទ្ធផលនៃការអភិវឌ្ឍសមត្ថភាព

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន៖

- តាមដានលើការអនុវត្តចំណេះដឹង និងជំនាញដែលទទួលបានពីកម្មវិធីអភិវឌ្ឍសមត្ថភាពនៅក្នុងការងារជាក់ស្តែងរបស់រដ្ឋបាលមូលដ្ឋាន អង្គភាពផ្តល់សេវា CAF និងសហគមន៍។
- វាយតម្លៃលើប្រសិទ្ធភាពនៃការអភិវឌ្ឍសមត្ថភាព ប្រមូលមតិយោបល់ពីអ្នកចូលរួម និងស្ថាប័នពាក់ព័ន្ធ ដើម្បីកែលម្អកម្មវិធី និងវិធីសាស្ត្រអភិវឌ្ឍសមត្ថភាពជាប្រចាំ
- ប្រើប្រាស់លទ្ធផលវាយតម្លៃសម្រាប់ការកែសម្រួល TNA ផែនការ និងកម្មវិធីអភិវឌ្ឍសមត្ថភាពជាបន្តបន្ទាប់។

**តារាងសូចនាករ និងចំណុចដៅសកម្មភាពជាអាទិភាពនៃលទ្ធផលរំពឹងទុក៣.៣**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

## សមាសភាគទី ៤ ៖ ការធ្វើសមាហរណកម្មគណនេយ្យភាពសង្គមនៅក្នុងផែនការរបស់រដ្ឋបាលមូលដ្ឋាន

### សនិទានភាព

បទពិសោធន៍នៃការអនុវត្តគណនេយ្យភាពសង្គមបានបង្ហាញថា ព័ត៌មាន មតិយោបល់ តម្រូវការ និងទិន្នន័យដែលប្រមូលបានពីប្រជាពលរដ្ឋ និងសហគមន៍តាមរយៈយន្តការគណនេយ្យភាពសង្គម គឺជាធាតុចូលដ៏មានសារៈសំខាន់សម្រាប់ការកំណត់បញ្ហា កំណត់អាទិភាព រៀបចំគម្រោង និងកែលម្អការផ្តល់សេវាសាធារណៈឱ្យឆ្លើយតបកាន់តែល្អប្រសើរទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។

ប្រសិនបើធាតុចូល និងលទ្ធផលដែលកើតចេញពីដំណើរការគណនេយ្យភាពសង្គមមិនត្រូវបានធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធកសាងផែនការនិងថវិការបស់រដ្ឋបាលមូលដ្ឋានទេ នោះការអនុវត្តគណនេយ្យភាពសង្គមនឹងនៅតែជាដំណើរការដាច់ដោយឡែកពីប្រព័ន្ធគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន និងការសម្រេចចិត្តលើការប្រើប្រាស់ធនធានសាធារណៈ។ ជាពិសេស បញ្ហាប្រឈម និងតម្រូវការដែលប្រជាពលរដ្ឋបានកំណត់ រួមទាំងសកម្មភាពដែលបានកំណត់ក្នុងផែនការសកម្មភាពរួម ស្តីពីការងារគណនេយ្យភាពសង្គម (JAAP) អាចនៅតែពឹងផ្អែកលើគម្រោង ឬការគាំទ្រពីខាងក្រៅ ដើម្បីអនុវត្ត និងឆ្លើយតប។

ការធ្វើសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធកសាងផែនការ និងថវិការបស់រដ្ឋបាលមូលដ្ឋាន គឺជាកត្តាសំខាន់សម្រាប់ធានាថា សម្លេង មតិយោបល់ និងអាទិភាពរបស់ប្រជាពលរដ្ឋត្រូវបានបម្លែងទៅជាសកម្មភាព និងគម្រោងអាទិភាព ដែលមានការបែងចែកធនធាន និងការទទួលខុសត្រូវច្បាស់លាស់សម្រាប់ការអនុវត្ត។ ប្រការនេះនឹងជួយពង្រឹងភាពជាម្ចាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ កាត់បន្ថយការពឹងផ្អែកលើការគាំទ្រពីខាងក្រៅ និងធានាបាននូវភាពធន់ និងចីរភាពនៃការឆ្លើយតបទៅនឹងតម្រូវការ និងអាទិភាពរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

ដូច្នេះ សមាសភាគទី៤ មានគោលបំណងពង្រឹងការផ្សារភ្ជាប់រវាងដំណើរការគណនេយ្យភាពសង្គមជាមួយនឹងដំណើរការកសាងផែនការ កម្មវិធីវិនិយោគ និងថវិការបស់រដ្ឋបាលមូលដ្ឋាន។ ប្រការនេះនឹងជួយឱ្យរដ្ឋបាលមូលដ្ឋានអាចទទួលបានព័ត៌មាន ធាតុចូលពីប្រជាពលរដ្ឋយកមកប្រើប្រាស់ក្នុងការកំណត់អាទិភាព និងរៀបចំការឆ្លើយតបបានកាន់តែល្អប្រសើរ ព្រមទាំងបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់រដ្ឋបាលមូលដ្ឋានលើការងារគណនេយ្យភាពសង្គម។

ជាមួយគ្នានេះ ការធ្វើសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធកសាងផែនការ និងថវិការបស់រដ្ឋបាលមូលដ្ឋាននឹងជួយបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន និងបង្កើតមូលដ្ឋានសម្រាប់ធានានិរន្តរភាពនៃគណនេយ្យភាពសង្គម ទោះបីការគាំទ្រពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលមានការថយចុះក៏ដោយ។

### សមិទ្ធផលរំពឹងទុក ៖

ដំណើរការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌត្រូវបានកែលម្អ តាមរយៈការធ្វើសមាហរណកម្មវិធីសាស្ត្រ ទិន្នន័យ និងឧបករណ៍នៃគណនេយ្យភាពសង្គម ដើម្បីពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ និងធានានិរន្តរភាពនៃគណនេយ្យភាពសង្គម។

ដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកខាងលើ សមាសភាគទី៤បានកំណត់នូវលទ្ធផលរំពឹងទុកចំនួន០២ រួមមាន ៖

**លទ្ធផលរំពឹងទុកទី ៤.១ ៖**

ដំណើរការ វិធីសាស្ត្រ ទិន្នន័យ និងឧបករណ៍នៃគណនេយ្យភាពសង្គមត្រូវបានធ្វើសមាហរណកម្មទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ ដើម្បីពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ និងធានានិរន្តរភាពនៃការងារគណនេយ្យភាពសង្គម។

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទី៤.១ រួមមាន ៖

**សកម្មភាពជាអាទិភាព ៤.១.១ ៖ ពិនិត្យ និងកែលម្អដំណើរការរៀបចំផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគរបស់រដ្ឋបាលឃុំ សង្កាត់ ដោយធ្វើសមាហរណកម្មគណនេយ្យភាពសង្គម**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- សិក្សា និងវិភាគចំណុចប្រសព្វដែលអាចធ្វើសមាហរណកម្មវិធីសាស្ត្រ ទិន្នន័យ និងឧបករណ៍នៃគណនេយ្យភាពសង្គមទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់
- ផ្អែកលើលទ្ធផលនៃការសិក្សា ត្រូវពិនិត្យ និងកែសម្រួលសេចក្តីណែនាំបច្ចេកទេសស្តីពីដំណើរការកសាងផែនការអភិវឌ្ឍ៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំលិករបស់ឃុំ សង្កាត់ ដោយធានាដល់ការដាក់បញ្ចូលនូវវិធីសាស្ត្រ ទិន្នន័យ និងឧបករណ៍វិភាគទិន្នន័យនៃការងារគណនេយ្យភាពសង្គម
- ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តសេចក្តីណែនាំបច្ចេកទេសស្តីពីដំណើរការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលឃុំ សង្កាត់ដែលបានកែលម្អ

**សកម្មភាពជាអាទិភាព ៤.១.២ ៖ ពិនិត្យ និងកែលម្អដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ ដោយធ្វើសមាហរណកម្មគណនេយ្យភាពសង្គម**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- សិក្សា ដើម្បីធ្វើសមាហរណកម្មដំណើរការ វិធីសាស្ត្រ ឧបករណ៍នានានៃការងារគណនេយ្យភាពសង្គមទៅក្នុងដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់
- ផ្អែកលើលទ្ធផលនៃការសិក្សា ត្រូវពិនិត្យ និងកែលម្អសារាចរណែនាំបច្ចេកទេសពាក់ព័ន្ធនឹងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ដោយធានាដល់ការដាក់បញ្ចូលនូវវិធីសាស្ត្រ និងឧបករណ៍នៃការងារគណនេយ្យភាពសង្គម
- ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តសារាចរណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធនឹងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ដែលបានកែលម្អ

### តារាងសូចនាករ និងចំណុចដៅសកម្មភាពជាអាទិភាពនៃលទ្ធផលរំពឹងទុក៤.១

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

**លទ្ធផលរំពឹងទុកទី ៤.២ ៖**

ដំណើរការ វិធីសាស្ត្រ ទិន្នន័យ ឧបករណ៍វិភាគទិន្នន័យនៃគណនេយ្យភាពសង្គមត្រូវបានធ្វើសមាហរណកម្មទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល និងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធានាការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងនិរន្តរភាពការងារគណនេយ្យភាពសង្គម។

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទី៤.២ រួមមាន ៖

**សកម្មភាពជាអាទិភាព ៤.២.១.៖ កែសម្រួលដំណើរការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ ដោយធ្វើសមាហរណកម្មការងារគណនេយ្យភាពសង្គម**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- សិក្សា និងវិភាគចំណុចប្រសព្វដែលអាចធ្វើសមាហរណកម្មវិធីសាស្ត្រ ទិន្នន័យ និងឧបករណ៍នៃគណនេយ្យភាពសង្គមទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុង ស្រុក ខណ្ឌ
- ផ្អែកលើលទ្ធផលនៃការសិក្សា ត្រូវពិនិត្យ និងកែសម្រួលសេចក្តីណែនាំបច្ចេកទេសស្តីពីដំណើរការកសាងផែនការអភិវឌ្ឍ៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំលិករបស់ក្រុង ស្រុក ខណ្ឌ ដោយធានាដល់ការដាក់បញ្ចូលនូវវិធីសាស្ត្រ ទិន្នន័យ និងឧបករណ៍វិភាគទិន្នន័យនៃការងារគណនេយ្យភាពសង្គម
- ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តសេចក្តីណែនាំបច្ចេកទេសស្តីពីដំណើរការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានកែលម្អ

**សកម្មភាពជាអាទិភាព ៤.២.២ ៖ ពិនិត្យ និងកែលម្អដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដោយធ្វើសមាហរណកម្មគណនេយ្យភាពសង្គម**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- សិក្សា ដើម្បីធ្វើសមាហរណកម្មដំណើរការ វិធីសាស្ត្រ ឧបករណ៍នានានៃការងារគណនេយ្យភាពសង្គមទៅក្នុងដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ផ្អែកលើលទ្ធផលនៃការសិក្សា ត្រូវពិនិត្យ និងកែលម្អសារាចរណែនាំបច្ចេកទេសពាក់ព័ន្ធនឹងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុង ស្រុក ខណ្ឌ ដោយធានាដល់ការដាក់បញ្ចូលនូវវិធីសាស្ត្រ និងឧបករណ៍នៃការងារគណនេយ្យភាពសង្គម
- ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តសារាចរណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធនឹងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុង ស្រុក ខណ្ឌដែលបានកែលម្អ

**តារាងសូចនាករ និងចំណុចដៅសកម្មភាពជាអាទិភាពនៃលទ្ធផលរំពឹងទុក៤.១**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

សេចក្តីព្រាង

## សមាសភាគទី ៥ ÷ ការអនុវត្ត និងការពង្រីកគណនេយ្យភាពសង្គមនៅតាមរដ្ឋបាលមូលដ្ឋាន

### សនិទានភាព

ការអនុវត្តគណនេយ្យភាពសង្គមក្នុងរយៈពេលកន្លងមកបានបង្កើតនូវមូលដ្ឋាន បទពិសោធន៍ យន្តការ និងឧបករណ៍សំខាន់ៗសម្រាប់លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងពង្រឹងការឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវានានា។ តាមរយៈការផ្តល់ព័ត៌មានជាសាធារណៈ ការវាយតម្លៃគុណភាពសេវា ការកំណត់បញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋ និងការរៀបចំផែនការសកម្មភាពរួម ស្តីពីការងារគណនេយ្យភាពសង្គម (JAAP) គណនេយ្យភាពសង្គមបានរួមចំណែកធ្វើឱ្យការផ្តល់សេវាសាធារណៈកាន់តែឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ និងសហគមន៍។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបាន បទពិសោធន៍នៃការអនុវត្តក៏បានបង្ហាញថា ការអនុវត្តគណនេយ្យភាពសង្គមនៅមិនទាន់គ្របដណ្តប់គ្រប់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌទូទាំងប្រទេសនៅឡើយ ហើយកម្រិតនៃការអនុវត្ត និងសមត្ថភាពរបស់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌនីមួយៗនៅមានភាពខុសគ្នា។ ដូច្នេះ ការពង្រឹង និងពង្រីកការអនុវត្តគណនេយ្យភាពសង្គមទៅកាន់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌដែលនៅសេសសល់ គឺជាកត្តាចាំបាច់ ដើម្បីធានាឱ្យប្រជាពលរដ្ឋនៅគ្រប់មូលដ្ឋានមានឱកាសចូលរួមក្នុងការតាមដាន វាយតម្លៃ និងផ្តល់មតិយោបល់លើការផ្តល់សេវាសាធារណៈ ហើយរដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌអាចប្រើប្រាស់ព័ត៌មាន និងមតិយោបល់ទាំងនេះសម្រាប់កែលម្អការអនុវត្តការងារ និងការផ្តល់សេវាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ជាមួយគ្នានេះ បទពិសោធន៍បានបង្ហាញថា ដើម្បីធានានិរន្តរភាពនៃគណនេយ្យភាពសង្គម ការអនុវត្តមិនគួរត្រូវបានចាត់ទុកជាសកម្មភាពដែលពឹងផ្អែកជាចម្បងលើការគាំទ្រពីគម្រោង និងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនោះទេ។ ព័ត៌មាន មតិយោបល់ តម្រូវការ និងអាទិភាពដែលបានកំណត់តាមរយៈដំណើរការគណនេយ្យភាពសង្គម ជាពិសេសលទ្ធផលពីការវាយតម្លៃ និងផែនការសកម្មភាពរួម ស្តីពីការងារគណនេយ្យភាពសង្គម (JAAP) ត្រូវបានបម្លែងទៅជាធាតុចូលសម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ។ ការធ្វើសមាហរណកម្មបែបនេះនឹងធានាថា បញ្ហាប្រឈម និងតម្រូវការរបស់ប្រជាពលរដ្ឋត្រូវបានយកមកពិចារណាក្នុងការកំណត់អាទិភាព និងការបែងចែកធនធានរបស់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌព្រមទាំងបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌលទ្ធផលនៃការអនុវត្តការងារ។

ការធ្វើសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធផែនការ កម្មវិធីវិនិយោគ និងថវិការបស់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌក៏មានសារៈសំខាន់សម្រាប់ការពង្រឹងការឆ្លើយតបរបស់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ និងធានាឱ្យសកម្មភាពដែលកើតចេញពីដំណើរការគណនេយ្យភាពសង្គមអាចទទួលបានការគាំទ្រ និងអនុវត្តតាមប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ បង្កើនការប្រើប្រាស់ធនធានរបស់ឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌឱ្យកាន់តែមានប្រសិទ្ធភាព និងរួមចំណែកពង្រឹងភាពជន់ និងធានានិរន្តរភាព។

ម្យ៉ាងទៀត ក្នុងបរិបទនៃការអនុវត្តគណនេយ្យភាពសង្គមកំពុងមានការផ្លាស់ប្តូរ ការពង្រឹងតួនាទី និងសមត្ថភាពរបស់អ្នកសម្របសម្រួលគណនេយ្យភាពសង្គម (CAF) និងបណ្តាញ CAF ត្រូវបានចាត់ទុកជាកត្តាសំខាន់សម្រាប់រក្សា និងពង្រីកការចូលរួមរបស់ប្រជាពលរដ្ឋ ព្រមទាំងជួយសម្របសម្រួលការទំនាក់ទំនង និងកិច្ចសហការរវាងប្រជាពលរដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវា។ ដូច្នេះ តួនាទី ភារកិច្ច និងសមត្ថភាពរបស់ CAF ចាំបាច់ត្រូវបានពិនិត្យ និងកែលម្អឱ្យស្របតាមបរិបទថ្មី ព្រមទាំងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីពង្រីកការផ្សព្វផ្សាយព័ត៌មាន ការទំនាក់ទំនង និងឱកាសចូលរួមរបស់ប្រជាពលរដ្ឋឱ្យកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាព។

ក្នុងន័យនេះ សមាសភាគទី៥ផ្តោតលើការពង្រឹង និងពង្រីកការអនុវត្តគណនេយ្យភាពសង្គមនៅតាមរដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ព្រមទាំងពង្រឹងការធ្វើសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធផែនការ កម្មវិធីវិនិយោគ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងកែលម្អតួនាទី និងសមត្ថភាពរបស់ CAF និងបណ្តាញ CAF។ ការអនុវត្តវិធានការទាំងនេះនឹងរួមចំណែកធ្វើឱ្យគណនេយ្យភាពសង្គមក្លាយជាផ្នែកមួយនៃប្រព័ន្ធអភិបាលកិច្ចនៅមូលដ្ឋាន ដែលមានភាពជាម្ចាស់ ប្រសិទ្ធភាព ការចូលរួម និងនិរន្តរភាព ព្រមទាំងអាចឆ្លើយតបបានកាន់តែល្អប្រសើរទៅនឹងបញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋ។

**សមិទ្ធផលរំពឹងទុក ៖**

ការអនុវត្តគណនេយ្យភាពសង្គមត្រូវបានពង្រឹង ពង្រីក និងមាននិរន្តរភាពនៅតាមរដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។

ដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកខាងលើ សមាសភាគទី៥បានកំណត់លទ្ធផលរំពឹងទុកចំនួន០៣ រួមមាន ៖

**លទ្ធផលរំពឹងទុកទី ៥.១ ៖**

គណនេយ្យភាពសង្គមត្រូវបានអនុវត្តនៅតាមរដ្ឋបាលឃុំ សង្កាត់ទូទាំងប្រទេសប្រកបដោយប្រសិទ្ធភាព ការចូលរួម និងនិរន្តរភាព។

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទី៥.១ រួមមាន ៖

### សកម្មភាពជាអាទិភាព ៥.១.១៖ ពង្រឹង និងពង្រីកការអនុវត្តគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់តាមយន្តការដែលមានស្រាប់

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- ពង្រឹងការអនុវត្តការងារគណនេយ្យភាពសង្គមនៅតាមរដ្ឋបាលឃុំ សង្កាត់គោលដៅ តាមយន្តការដែលមានស្រាប់នាបច្ចុប្បន្ន ជាពិសេសការអនុវត្តតាមយុទ្ធសាស្ត្រនិរន្តភាពស្តីពីនិរន្តរភាពនៃការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ និងសៀវភៅណែនាំប្រតិបត្តិស្តីពីការងារគណនេយ្យភាពសង្គមឃុំ សង្កាត់ (ឆ្នាំ២០២៦)

- ពង្រីកការអនុវត្តការងារគណនេយ្យភាពសង្គមទៅរដ្ឋបាលឃុំ សង្កាត់ដែលនៅសេសសល់ តាមយុទ្ធសាស្ត្រនិរន្តភាពស្តីពីការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ និងសៀវភៅណែនាំប្រតិបត្តិស្តីពីការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ (ឆ្នាំ២០២៦)

**សកម្មភាពជាអាទិភាព ៥.១.២.៖ ពង្រឹងការធ្វើសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលឃុំ សង្កាត់**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- គាំទ្រ និងជំរុញរដ្ឋបាលឃុំ សង្កាត់ក្នុងការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលស្របតាមដំណើរការកសាងផែនការ និងកម្មវិធីវិនិយោគដែលបានធ្វើសមាហរណកម្មដំណើរការ វិធីសាស្ត្រ ឧបករណ៍នៃការងារគណនេយ្យភាពសង្គម (តាមសេចក្តីណែនាំបច្ចេកទេសដែលបានកែលម្អ)
- តាមដាន ត្រួតពិនិត្យ និងគាំទ្រដល់រដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលស្របតាមដំណើរការ និងនីតិវិធីដែលបានកែលម្អ

**សកម្មភាពជាអាទិភាព ៥.១.៣.៖ ពង្រឹងការធ្វើសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងការរៀបចំ និងការអនុវត្តថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- គាំទ្រ និងជំរុញរដ្ឋបាលឃុំ សង្កាត់ក្នុងរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ស្របតាមសារាចរណ៍ណែនាំបច្ចេកទេសដែលបានកែលម្អ ។
- តាមដាន ត្រួតពិនិត្យ និងគាំទ្រដល់រដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តថវិកាប្រចាំឆ្នាំស្របតាមស្របតាមសារាចរណ៍ណែនាំបច្ចេកទេសដែលបានកែលម្អ ។

**តារាងសូចនាករ និងចំណុចដៅសកម្មភាពជាអាទិភាពនៃលទ្ធផលរំពឹងទុក៥.១**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

**លទ្ធផលរំពឹងទុកទី ៥.២ ៖**

គណនេយ្យភាពសង្គមត្រូវបានអនុវត្តនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ប្រកបដោយប្រសិទ្ធភាព ការចូលរួម និងនិរន្តរភាព។

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទី៥.២ រួមមាន ៖

**សកម្មភាពជាអាទិភាព ៥.២.១៖ ពង្រឹង និងពង្រីកការអនុវត្តគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌតាមយន្តការដែលមានស្រាប់**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- ពង្រឹងការអនុវត្តការងារគណនេយ្យភាពសង្គមនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌគោលដៅតាមយន្តការដែលមានស្រាប់ ជាពិសេសការអនុវត្តតាមនិងតាមសៀវភៅណែនាំប្រត្តិបត្តិស្តីពីការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ (២០២៦)
- ពង្រីកការអនុវត្តការងារគណនេយ្យភាពសង្គមទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលនៅសេសសល់តាមនិងតាមសៀវភៅណែនាំប្រត្តិបត្តិស្តីពីការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ (២០២៦)
- សិក្សា និងពង្រីកការអនុវត្តការងារគណនេយ្យភាពសង្គមគ្រប់ដណ្តប់លើប្រភេទសេវានានាបន្ថែមផ្សេងៗទៀតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**សកម្មភាពជាអាទិភាព ៥.២.២៖ ពង្រឹងការធ្វើសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- គាំទ្រ និងជំរុញរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលស្របតាមដំណើរការកសាងផែនការ និងកម្មវិធីវិនិយោគដែលបានធ្វើសមាហរណកម្មដំណើរការ វិធីសាស្ត្រ ឧបករណ៍នៃការងារគណនេយ្យភាពសង្គម (តាមសេចក្តីណែនាំបច្ចេកទេសដែលបានកែលម្អ)
- តាមដាន ត្រួតពិនិត្យ និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលស្របតាមដំណើរការ និងនីតិវិធីដែលបានកែលម្អ

**សកម្មភាពជាអាទិភាព ៥.២.៣៖ ពង្រឹងការធ្វើសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងការរៀបចំ និងការអនុវត្តថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- គាំទ្រ និងជំរុញរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ស្របតាមសារាចរណ៍ណែនាំបច្ចេកទេសដែលបានកែលម្អ ។
- តាមដាន ត្រួតពិនិត្យ និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តថវិកាប្រចាំឆ្នាំស្របតាមស្របតាមសារាចរណ៍ណែនាំបច្ចេកទេសដែលបានកែលម្អ ។

**តារាងសូចនាករ និងចំណុចដៅសកម្មភាពជាអាទិភាពនៃលទ្ធផលរំពឹងទុក៥.២**

| ល.រ. | សូចនាករ | ចំណុចដៅ |
| --- | --- | --- |

| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

**លទ្ធផលរំពឹងទុកទី៥.៣៖**

អ្នកសម្របសម្រួលគណនេយ្យភាពសង្គម (CAF) និងបណ្តាញ CAF ត្រូវបានពង្រឹង និងរៀបចំឱ្យមានតួនាទីសមស្រប ដើម្បីគាំទ្រការចូលរួមរបស់ប្រជាពលរដ្ឋ និងការអនុវត្តគណនេយ្យភាពសង្គមនៅតាមមូលដ្ឋានក្នុងបរិបទថ្មី។

**សកម្មភាពជាអាទិភាព ៥.៣.១៖ ពង្រឹងសមត្ថភាព និងតួនាទីរបស់អ្នកសម្របសម្រួលគណនេយ្យភាពសង្គម (CAF) ក្នុងការគាំទ្រការចូលរួមរបស់ប្រជាពលរដ្ឋ និងការអនុវត្តគណនេយ្យភាពសង្គម**

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន៖

- ពិនិត្យ និងកែលម្អតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ CAF ឱ្យស្របតាមតម្រូវការនៃការអនុវត្តគណនេយ្យភាពសង្គមក្នុងបរិបទថ្មី។
- ពង្រឹងសមត្ថភាព CAF តាមរយៈការបណ្តុះបណ្តាល ការណែនាំតម្រង់ទិស និងការគាំទ្របច្ចេកទេសអំពីការអនុវត្តគណនេយ្យភាពសង្គមក្នុងបរិបទថ្មី។
- រៀបចំឧបករណ៍ និងសម្ភារៈណែនាំសម្រាប់ CAF ដើម្បីគាំទ្រការចូលរួមរបស់ប្រជាពលរដ្ឋ ការប្រមូលមតិយោបល់ និងការតាមដានការឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមបរិបទថ្មី
- ជំរុញ និងពង្រឹងសមត្ថភាព CAF ក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលធ្វើជាមធ្យោបាយទំនាក់ទំនង ពង្រីកការចែករំលែកព័ត៌មាន និងការចូលរួមរបស់ប្រជាពលរដ្ឋតាមបរិបទថ្មី។

**តារាងសូចនាករ និងចំណុចដៅសកម្មភាពជាអាទិភាពនៃលទ្ធផលរំពឹងទុក៥.៣**

| ល.រ. | សូចនាករ | ចំណុចដៅ | | | | | |
|---|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

# ជំពូកទី៣

# ការគ្រប់គ្រង និងការអនុវត្តផែនការ

## ១. ការអនុវត្ត

ការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី៣ ស្ថិតក្រោមការដឹកនាំរបស់ គ.ជ.អ.ប. ដែលមានគណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ (គ.គ.អ.ស.) និងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាសេនាធិការ។

នៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ ការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី៣ ស្ថិតក្រោមការដឹកនាំ និងការសម្របសម្រួលរបស់គណៈកម្មាធិការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (គ.ជ.វ.វ.) ដោយមានការជួយគាំទ្រពីមន្ត្រីបង្គោលគណនេយ្យភាពសង្គម។

នៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី៣ ស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រដ្ឋបាលសាមី ដោយមានការសម្របសម្រួលរបស់ក្រុមការងារគណនេយ្យភាពសង្គម ឬគណៈកម្មាធិការគណនេយ្យភាពសង្គម និងការគាំទ្រផ្នែកបច្ចេកទេសពីមន្ត្រីបង្គោលគណនេយ្យភាពសង្គម និងដោយសហការជិតស្និទ្ធជាមួយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងបណ្តាញអ្នកសម្របសម្រួលសហគមន៍។

នៅថ្នាក់ឃុំ សង្កាត់ ការអនុវត្តគណនេយ្យភាពសង្គម ស្ថិតក្រោមការដឹកនាំ និងសម្របសម្រួលរបស់មេឃុំ ចៅសង្កាត់ ដែលមានគណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមជាសេនាធិការ និងមានការជួយគាំទ្រពីមន្ត្រីបង្គោលគណនេយ្យភាពសង្គម និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។

ការអនុវត្តផែនការនេះ ត្រូវធ្វើឡើងតាមរយៈផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមដែលត្រូវរៀបចំ និងអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានា។ ក្នុងន័យនេះ ជារៀងរាល់ឆ្នាំ ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធត្រូវកំណត់ និងបញ្ចូលសកម្មភាពជាអាទិភាពនៃការងារគណនេយ្យភាពទៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួន។

លេខាធិការដ្ឋាន គ.ជ.អ.ប. ដែលមានអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មានជាសេនាធិការត្រូវសម្របសម្រួល និងតាមដានត្រួតពិនិត្យជាប្រចាំលើការអនុវត្តផែនការអនុវត្តការងារគណនេយ្យភាពសង្គម រួមបញ្ចូលទាំងការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម។ ទន្ទឹមនេះ អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប. ក៏មានភារកិច្ចក្នុងការសម្របសម្រួល និងផ្តល់ការគាំទ្រដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធក្នុងការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដែលបានដាក់បញ្ចូលសកម្មភាពគណនេយ្យភាពសង្គម ដោយសហការជិតស្និទ្ធជាមួយអង្គភាពគ្រប់គ្រង

និងគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.អ.ប.។

លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវពង្រឹងការសម្របសម្រួល កិច្ចសហការ និងការកៀរគរធនធានពីដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធនានាសម្រាប់អនុវត្តការងារគណនេយ្យភាពសង្គម។

## ២. ការត្រួតពិនិត្យ និងការវាយតម្លៃ

លេខាធិការដ្ឋាន គ.ជ.អ.ប. ដែលមានអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មានជាសេនាធិការត្រូវទទួលខុសត្រូវលើការត្រួតពិនិត្យ និងការវាយតម្លៃជាប្រចាំលើការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី៣ (ISAF-III) ដោយសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានា។

ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី៣នេះ រួមមាន ៖

- ការរៀបចំរបាយការណ៍របាយការណ៍ប្រចាំខែ របាយការប្រចាំឆមាស និងរបាយការណ៍ប្រចាំឆ្នាំដែលត្រូវដាក់បញ្ចូលទៅក្នុងការរបាយការណ៍ប្រចាំខែ ប្រចាំឆមាស និងរបាយការណ៍ប្រចាំឆ្នាំរបស់ គ.ជ.អ.ប. តាមការកំណត់
- ការវាយតម្លៃប្រចាំឆ្នាំ
- ការវាយតម្លៃពាក់កណ្តាលអាណត្តិ
- ការវាយតម្លៃចុងបញ្ចប់នៃផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី៣

## ៣. ការគ្រប់គ្រងហានិភ័យ

ផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី៣ (២០២៦-២០៣០) នឹងត្រូវអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា។

ដើម្បីធានាការអនុវត្តដោយជោគជ័យនូវផែនការអនុវត្តគណនេយ្យភាពសង្គម ហានិភ័យសំខាន់ៗមួយចំនួនដែលអាចកើតឡើង រួមបញ្ចូលវិធានការកាត់បន្ថយ និងស្ថាប័នទទួលខុសត្រូវ ត្រូវបានកំណត់ដូចមានបរិយាយនៅក្នុងតារាងខាងក្រោម៖

### ការគ្រប់គ្រងហានិភ័យ

| ហានិភ័យ | ឱកាសអាចកើតមាន | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ការធ្វើស្ថាប័នភាវូបនីយកម្មនៃយន្តការគណនេយ្យភាពសង្គមក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធរបស់រដ្ឋមានភាពរអាក់រអួល | មធ្យម | ខ្ពស់ | – រៀបចំផែនទីបង្ហាញផ្លូវ និងលិខិតបទដ្ឋានគតិយុត្តឱ្យបានច្បាស់លាស់មុននឹងការធ្វើស្ថាប័នភាវូបនីយកម្ម<br>– ត្រួតពិនិត្យ និងផ្តល់ការគាំទ្រជាប្រចាំដល់ស្ថាប័នពាក់ព័ន្ធក្នុងការធ្វើស្ថាប័នភាវូបនីយកម្ម | – លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>– រដ្ឋបាលថ្នាក់ក្រោមជាតិ |

| ហានិភ័យ | ទំនងអាចកើតមាន | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ |
| --- | --- | --- | --- | --- |
| ការផ្ទេរសមាហរណកម្មគណៈកម្មាធិការ ផ.ស.រ.គ. ទៅក្នុង គ.ក.ន.ក នាំឱ្យថយចុះប្រសិទ្ធភាពក្នុងការបំពេញការងាររបស់គណៈកម្មាធិការនេះ | មធ្យម | ខ្ពស់ | – ពង្រឹងការបណ្តុះបណ្តាល និងគាំទ្រការបំពេញតួនាទី និងភារកិច្ចថ្មីរបស់ គ.ក.ន.ក.<br>– សិក្សាអំពីជម្រើសក្នុងការបង្កើតគណៈកម្មាធិការ ផ.ស.រ.គ. មួយដោយឡែករបស់ក្រុមប្រឹក្សាឃុំសង្កាត់ | – លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ការផ្ទេរការទទួលខុសត្រូវបណ្តើរៗពីលេខាធិការដ្ឋាន គ.ជ.អ.ប. ទៅឱ្យ NASLA ក្នុងការបណ្តុះបណ្តាលអំពីការងារគណនេយ្យភាពសង្គមជួបបញ្ហាប្រឈម ដោយសាលាជាតិខ្វះធនធាន និងបុគ្គលិក | ខ្ពស់ | មធ្យម | – កំណត់ឱ្យបានច្បាស់លាស់នូវកិច្ចការដែលត្រូវផ្ទេរទៅឱ្យសាលាជាតិ<br>– អនុវត្តជាដំណាក់កាលនូវការផ្ទេរការទទួលខុសត្រូវទៅឱ្យសាលាជាតិ<br>– ត្រួតពិនិត្យ និងគាំទ្រសាលាជាតិជាប្រចាំក្នុងដំណាក់កាលនៃការផ្ទេរការទទួលខុសត្រូវ | – លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– សាលាជាតិរដ្ឋបាលមូលដ្ឋាន |
| មន្ត្រី និង CAFs ដែលទទួលបានការបណ្តុះបណ្តាលបានចាកចេញ ឬផ្លាស់ប្តូរមុខតំណែងជាញឹកញាប់ | ខ្ពស់ | មធ្យម | – រៀបចំ និងដាក់ឱ្យដំណើរការប្រព័ន្ធសិក្សាអនឡាញ<br>– រៀបចំ និងចងក្រងឯកសារបណ្តុះបណ្តាលជាស្តង់ដា ដើម្បីងាយស្រួលបណ្តុះបណ្តាលមន្ត្រី និង CAFs ថ្មី<br>– រៀបចំ និងដាក់ចេញនូវប្រព័ន្ធលើកទឹកចិត្តសម្រាប់ CAFs | – លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>– រាជធានី ខេត្ត |
| ការសិក្សា និងកែសម្រួលសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការថ្នាក់ក្រោមជាតិ ដោយបញ្ចូលការងារគណនេយ្យភាពសង្គម ខ្វះការគាំទ្រ និងចូលរួមពីភាគីពាក់ព័ន្ធ ហើយដំណើរការមានភាពរអាក់រអួល | មធ្យម | ខ្ពស់ | – បង្កើតក្រុមការងារច្បាស់លាស់ ដើម្បីទទួលការងារនេះ<br>– រៀបចំផែនការសកម្មភាពការសិក្សា និងកែសម្រួលសេចក្តីណែនាំបច្ចេកទេស ដោយថវិកាគាំទ្រគ្រប់គ្រាន់<br>– បង្កើនកិច្ចសហការ និងសម្របសម្រួលជាប្រចាំ និងជិតស្និទ្ធជាមួយក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានាពីដំណាក់កាលដំបូងនៃការរៀបចំ | – លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– ក្រសួងផែនការ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងស្ថាប័នពាក់ព័ន្ធនានា |
| ការពិនិត្យ និងកែសម្រួលសៀវភៅណែនាំនានាស្តីពីការអនុវត្តគម្រោងសកម្មភាពរបស់ថ្នាក់ក្រោមជាតិ | មធ្យម | ខ្ពស់ | – បង្កើតក្រុមការងារច្បាស់លាស់ ដើម្បីទទួលការងារនេះ | – លេខាធិការដ្ឋាន គ.ជ.អ.ប. |

| ហានិភ័យ | ភាពអាចកើតមាន | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ដោយបញ្ចូលការងារគណនេយ្យភាពសង្គម ខ្វះការគាំទ្រ និងចូលរួមពីភាគីពាក់ព័ន្ធ ហើយដំណើរការមានភាពរអាក់រអួល | | | – រៀបចំផែនការសកម្មភាពការសិក្សា និងកែសម្រួលសេចក្តីណែនាំបច្ចេកទេស ដោយថវិកាគាំទ្រគ្រប់គ្រាន់<br>– បង្កើនកិច្ចសហការ និងសម្របសម្រួលជាប្រចាំ និងជិតស្និទ្ធជាមួយក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានាពីដំណាក់កាលដំបូងនៃការរៀបចំ | – ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងស្ថាប័នពាក់ព័ន្ធនានា |
| ប្រសិទ្ធភាព និងគុណភាពមានកម្រិតទាបនៃការអនុវត្តការងារគណនេយ្យភាពសង្គមនៅក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ថ្មី | មធ្យម | ខ្ពស់ | – អនុវត្តជាដំណាក់កាលនូវការពង្រីកការងារគណនេយ្យភាពសង្គមនៅក្នុងក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ថ្មី<br>– លើកកម្ពស់ការសិក្សារៀនសូត្រពីគ្នាទៅវិញទៅមក | – លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ |
| បញ្ហាបច្ចេកវិទ្យា សេវាអិនធឺណិត និងសមត្ថភាពមានកម្រិតផ្នែកបច្ចេកវិទ្យារបស់មន្ត្រីប្រជាពលរដ្ឋនៅតាមតំបន់ដាច់ជនបទ | មធ្យម | មធ្យម | – រៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធឌីជីថលនៃការងារគណនេយ្យភាពសង្គម ដែលងាយស្រួលប្រើប្រាស់ និងអាចប្រើប្រាស់បាននៅពេលមិនមានសេវាអិនធឺណិត | – លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– រដ្ឋបាលថ្នាក់ក្រោមជាតិ |

# ឧបសម្ព័ន្ធទី ៤
# ផែនការថវិកា

## ១. ការប៉ាន់ស្មានចំណាយ

ការប៉ាន់ស្មានចំណាយសរុបនៃ ផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី៣ ត្រូវបានគណនាដោយផ្អែកលើកិច្ចការនានា សកម្មភាពជាអាទិភាពដែលបានកំណត់នៅក្នុងលទ្ធផលរំពឹងទុកនីមួយៗនៃផែនការនេះ។ ការប៉ាន់ស្មានចំណាយសម្រាប់ផែនការអនុវត្តនេះ ផ្តោតជាសំខាន់លើចំណាយនានាដែលពាក់ព័ន្ធនឹងការអនុវត្តកិច្ចការនានាក្នុងសកម្មភាពជាអាទិភាពនីមួយៗ ដូចជាការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត ការអភិវឌ្ឍសមត្ថភាព ការរៀបចំកិច្ចប្រជុំនិងសិក្ខាសាលាផ្សព្វផ្សាយ ការសិក្សាវាយតម្លៃ ការរៀបចំនិងដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធនិងប្រព័ន្ធនានា និងចំណាយសម្រាប់ការត្រួតពិនិត្យ និងការវាយតម្លៃជាដើម។

ចំណាយប៉ាន់ស្មានសរុបរបស់ ផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី៣ មានចំនួន ........................លានរៀល សមមូលនឹង...................លានដុល្លារអាមេរិក សម្រាប់រយៈពេល០៥ឆ្នាំចាប់ពីឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០ ដូចបង្ហាញតាមឆ្នាំនៃសមាសភាគនីមួយៗក្នុងតារាងខាងក្រោម។ ជាមធ្យមការអនុវត្ត ផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី៣ ត្រូវការថវិកាចំនួន .....................លានរៀល សមមូលនឹង ...................លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។

## ២. ប្រភពថវិកា

ប្រភពមូលនិធិសំខាន់ៗ សម្រាប់គាំទ្រការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី៣រួមមាន ៖

- **ថវិការបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ** ៖ ថវិកាសម្រាប់អនុវត្តផែនការអនុវត្ត គឺជាផ្នែកមួយនៃថវិការបស់ក្រសួង ស្ថាប័នសម្រាប់អនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ស្របតាមការទទួលខុសត្រូវរបស់ខ្លួន ដូចបានកំណត់នៅក្នុង ផអ៥ទី២ នៃ កជទី២។
- **ថវិការបស់រដ្ឋបាលរាជធានី ខេត្ត និងខណ្ឌ** ៖ ថវិកាសម្រាប់អនុវត្តផែនការអនុវត្ត គឺជាផ្នែកមួយនៃថវិការបស់រដ្ឋបាលរាជធានី ខេត្ត និងខណ្ឌសម្រាប់អនុវត្តការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ស្របតាមការទទួលខុសត្រូវរបស់ខ្លួន ដូចបានកំណត់នៅក្នុង ផអ៥ទី២ នៃ កជទី២។ ក្រៅពីនេះ រដ្ឋបាលរាជធានី ខេត្ត និងខណ្ឌក៏មានថវិកាសម្រាប់អនុវត្តសេវាសង្គមដែលត្រូវវិភាជជារៀងរាល់ឆ្នាំយ៉ាងតិចចំនួន ១០% នៃថវិកាអភិវឌ្ឍ ឬថវិកាគុណប្រយោជន៍របស់រដ្ឋបាលរាជធានី ខេត្ត និងខណ្ឌ ស្របតាមការណែនាំរបស់ក្រសួងមហាផ្ទៃ។
- **ថវិការបស់មន្ទីរ អង្គភាពជំនាញថ្នាក់រាជធានី ខេត្ត** ៖ ថវិកាសម្រាប់អនុវត្តផែនការអនុវត្ត គឺជាផ្នែកមួយនៃថវិការបស់មន្ទីរ អង្គភាពជំនាញសម្រាប់អនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ស្របតាមការទទួលខុសត្រូវរបស់ខ្លួន ដូចបានកំណត់នៅក្នុង ផអ៥ទី២ នៃ ក

ជទី២។ ក្រៅពីនេះ ថវិការបស់មន្ទីរ អង្គភាពជំនាញក៏មានថវិកាដែលអាចគាំទ្រគម្រោងសកម្មភាពនានាដែលបានកំណត់ក្នុង ផ.ស.រ.គ.។

- **មូលនិធិក្រុង ស្រុក ៖** សម្រាប់រដ្ឋបាលក្រុង ស្រុក ថវិកាសម្រាប់អនុវត្តផែនការអនុវត្ត គឺជាផ្នែកមួយនៃមូលនិធិរបស់រដ្ឋបាលក្រុង ស្រុកសម្រាប់អនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ស្របតាមការទទួលខុសត្រូវរបស់ខ្លួន ដូចបានកំណត់នៅក្នុង ផអ៥ទី២ នៃ កជទី២។ ក្រៅពីនេះ រដ្ឋបាលក្រុង ស្រុក ក៏មានមូលនិធិសម្រាប់សេវាសង្គម និងអនាម័យបរិស្ថានដែល អាចប្រើប្រាស់សម្រាប់អនុវត្តផែនការនេះ។
- **មូលនិធិឃុំ សង្កាត់ ៖** សម្រាប់រដ្ឋបាលឃុំ សង្កាត់ ថវិកាសម្រាប់អនុវត្តផែនការអនុវត្ត គឺជាផ្នែកមួយនៃមូលនិធិរបស់រដ្ឋបាលឃុំ សង្កាត់សម្រាប់អនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ស្របតាមការទទួលខុសត្រូវរបស់ខ្លួន ដូចបានកំណត់នៅក្នុង ផអ៥ទី២ នៃ កជទី២។ ក្រៅពីនេះ រដ្ឋបាលឃុំ សង្កាត់ ក៏មានមូលនិធិសម្រាប់សេវាសង្គម និងអនាម័យបរិស្ថានដែលអាចប្រើប្រាស់សម្រាប់អនុវត្តផែនការនេះ។
- **ថវិកាដៃគូអភិវឌ្ឍន៍ ៖** ដៃគូអភិវឌ្ឍន៍សំខាន់ៗដែលមានសក្តានុពលក្នុងការរួមចំណែកគាំទ្រការអនុវត្តផែនការអនុវត្តស្តីពីការងារគណនេយ្យភាពសង្គម រួមមាន DFAT SDC WB GIZ/ISD...
- ថវិការបស់អង្គការសង្គមស៊ីវិលនានា ៖ អង្គការសង្គមស៊ីវិលដែលបាន និងសន្យាបន្តជួយគាំទ្រថវិកាសម្រាប់អនុវត្តផែនការ គឺអង្គការ WVI-C។ ក្នុងអំឡុងពេលនៃការអនុវត្តផែនការលេខាធិការដ្ឋាន គ.ជ.អ.ប. នឹងបន្តពង្រឹងកិច្ចសហការជាមួយអង្គការសង្គមស៊ីវិលនានា ដើម្បីកៀរគរធនធានសម្រាប់អនុវត្តផែនការនេះ។

# ជំពូកទី ៥

# សេចក្តីសន្និដ្ឋាន

ការអនុវត្តគណនេយ្យភាពសង្គមនៅក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងមក បានបង្កើតនូវមូលដ្ឋានសំខាន់ៗទាំងលិខិតបទដ្ឋានគតិយុត្ត យន្តការស្ថាប័ន សមត្ថភាព និងមេរៀន បទពិសោធន៍ជាក់ស្តែងដែលអាចធ្វើជាមូលដ្ឋានសម្រាប់ការបន្តអនុវត្តក្នុងដំណាក់កាលទី៣។ តាមរយៈ ISAF-I និង ISAF-II ការងារគណនេយ្យភាពសង្គមបានរួមចំណែកពង្រឹងការផ្សារភ្ជាប់រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋ តាមរយៈការផ្តល់ព័ត៌មាន ការចូលរួម ការតាមដាន និងវាយតម្លៃការផ្តល់សេវាសាធារណៈ និងការរៀបចំផែនការសកម្មភាពរួម ស្តីពីការងារគណនេយ្យភាពសង្គម (JAAP)។ សមិទ្ធផលទាំងនេះបានបង្ហាញថា គណនេយ្យភាពសង្គមអាចជួយបង្កើនការឆ្លើយតបរបស់រដ្ឋបាលមូលដ្ឋាន និងអង្គភាពផ្តល់សេវាទៅនឹងបញ្ហា និងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។

ទោះជាយ៉ាងណា បទពិសោធន៍នៃការអនុវត្តកន្លងមកក៏បានបង្ហាញពីបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយក្នុងដំណាក់កាលទី៣។ ក្នុងនោះ ការអនុវត្តគណនេយ្យភាពសង្គមនៅមិនទាន់គ្របដណ្តប់គ្រប់រដ្ឋបាលមូលដ្ឋាននៅឡើយ សមត្ថភាព និងគុណភាពនៃការអនុវត្តនៅមានភាពខុសគ្នា ហើយការអនុវត្តមួយចំនួននៅតែមានការពឹងផ្អែកលើការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីគម្រោងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល។ លើសពីនេះ ការផ្សារភ្ជាប់ដំណើរការគណនេយ្យភាពសង្គមទៅនឹងប្រព័ន្ធផែនការ កម្មវិធីវិនិយោគ និងថវិការបស់រដ្ឋបាលមូលដ្ឋាននៅមិនទាន់មានលក្ខណៈពេញលេញនៅឡើយ។

ដោយហេតុនេះ **ISAF-III (២០២៦–២០៣០) ត្រូវបានរៀបចំឡើងក្នុងបរិបទថ្មី ដោយមានការផ្លាស់ប្តូរទិសដៅពីការអនុវត្តដែលផ្អែកលើគម្រោងដែលគាំទ្រធនធានពីក្រៅ ឈានទៅការអនុវត្តដែលលើកកម្ពស់ភាពម្ចាស់ការ និងការទទួលខុសត្រូវកាន់តែខ្ពស់របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ**។ គោលដៅសំខាន់មិនមែនត្រឹមតែពង្រីកចំនួនរដ្ឋបាលដែលអនុវត្តគណនេយ្យភាពសង្គមនោះឡើយ ប៉ុន្តែត្រូវធានាឱ្យបានថាគណនេយ្យភាពសង្គមក្លាយជាផ្នែកមួយនៃប្រព័ន្ធអភិបាលកិច្ច ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រការនេះ ស្របនឹងទិសដៅសំខាន់របស់ ISAF-III ដែលផ្តោតលើការធ្វើស្ថាប័នភាវូបនីយកម្ម និងការពង្រឹងភាពជាម្ចាស់របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ដើម្បីសម្រេចបាននូវទិសដៅនេះ ការអនុវត្ត ISAF-III ត្រូវផ្តោតលើ **ការពង្រឹងប្រព័ន្ធ និងយន្តការគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការពង្រឹងសមត្ថភាព ការពង្រីកការអនុវត្តទៅគ្រប់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ និងការធ្វើសមាហរណកម្មដំណើរការ វិធីសាស្ត្រ ទិន្នន័យ និងឧបករណ៍គណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធការងាររបស់រដ្ឋបាលមូលដ្ឋាន**។ ទន្ទឹមនឹងនេះ ត្រូវបន្តពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ ដើម្បីធានាថា សម្លេង មតិយោបល់ បញ្ហាប្រឈម និងតម្រូវការរបស់ប្រជាពលរដ្ឋត្រូវ

បានយកមកពិចារណាក្នុងការកំណត់អាទិភាព ការរៀបចំផែនការ ការបែងចែកធនធាន និងការកែលម្អការផ្តល់សេវាសាធារណៈ។ ទិសដៅនេះត្រូវបានបង្ហាញយ៉ាងច្បាស់តាមរយៈសមាសភាគទី៤ និងទី៥ ដែលផ្តោតលើការធ្វើសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងផែនការ កម្មវិធីវិនិយោគ និងថវិការបស់រដ្ឋបាលមូលដ្ឋាន និងការពង្រីកការអនុវត្តទៅទូទាំងប្រទេស។

ជាមួយគ្នានេះ **និរន្តរភាព** ត្រូវបានចាត់ទុកជាគោលការណ៍ស្នូលមួយរបស់ ISAF-III។ ដើម្បីធានានិរន្តរភាពការងារគណនេយ្យភាពសង្គមត្រូវមានការគាំទ្រពីប្រព័ន្ធរដ្ឋទាំងផ្នែកស្ថាប័ន លិខិតបទដ្ឋានគតិយុត្ត សមត្ថភាព ធនធាន និងថវិកា។ រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើនការទទួលខុសត្រូវក្នុងការរៀបចំ និងបែងចែកធនធានសម្រាប់អនុវត្តការងារគណនេយ្យភាពសង្គម ស្របតាមតួនាទី និងភារកិច្ចរបស់ខ្លួន។ ក្នុងន័យនេះ ការធ្វើសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធផែនការ កម្មវិធីវិនិយោគ និងថវិកា គឺជាមធ្យោបាយសំខាន់ក្នុងការកាត់បន្ថយការពឹងផ្អែកលើធនធានខាងក្រៅ និងធានាឱ្យការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋអាចបន្តបានក្នុងរយៈពេលវែង។

ការពង្រឹង **ផ្នែកតម្រូវការ** ក៏ជាចំណុចសំខាន់ដែលមិនអាចខ្វះបាន។ ក្នុងដំណាក់កាលទី៣ ត្រូវបន្តពង្រឹងសមត្ថភាព និងតួនាទីរបស់អ្នកសម្របសម្រួលគណនេយ្យភាពសង្គម (CAF) និងបណ្តាញ CAF ក្នុងការផ្សព្វផ្សាយព័ត៌មាន ជំរុញការចូលរួម ប្រមូល និងបញ្ជូនមតិយោបល់ និងតម្រូវការរបស់ប្រជាពលរដ្ឋ ព្រមទាំងជួយផ្សារភ្ជាប់ប្រជាពលរដ្ឋជាមួយរដ្ឋបាលមូលដ្ឋាន និងអង្គភាពផ្តល់សេវា។ ទន្ទឹមនឹងនេះ ត្រូវរក្សាឱ្យបាននូវភាពអព្យាក្រឹតភាព ភាពជឿទុកចិត្ត និងតួនាទីជាយន្តការដែលផ្តល់សំឡេងដល់ប្រជាពលរដ្ឋ។ សមាសភាគទី៥ បានដាក់ចេញនូវទិសដៅពង្រឹងតួនាទី និងសមត្ថភាព CAF ឱ្យស្របតាមបរិបទថ្មី និងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់ការទំនាក់ទំនង និងការចូលរួម។

ជាមួយគ្នានេះ **ការអភិវឌ្ឍសមត្ថភាព និងការរៀនសូត្រជាប្រចាំ** ក៏ជាផ្នែកដ៏សំខាន់មួយនៃ ISAF-III ។ ប្រការនេះ ត្រូវពង្រឹងតួនាទីរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA) និងយន្តការអភិវឌ្ឍសមត្ថភាពរបស់រាជធានី ខេត្ត ព្រមទាំងប្រើប្រាស់ការបណ្តុះបណ្តាលជាក់ស្តែង ការគាំទ្របច្ចេកទេស ការរៀនសូត្រពីគ្នាទៅវិញទៅមក និងការរៀនតាមប្រព័ន្ធឌីជីថល ដើម្បីធានាថាចំណេះដឹង និងជំនាញអាចបន្តរក្សា និងអនុវត្តបាន ទោះបីមានការផ្លាស់ប្តូរបុគ្គលិក ឬការថយចុះនៃការគាំទ្រពីខាងក្រៅក៏ដោយ។

ដើម្បីធានាការអនុវត្ត ISAF-III ប្រកបដោយប្រសិទ្ធភាព ត្រូវមាន**ភាពម្ចាស់ការ ការទទួលខុសត្រូវ និងកិច្ចសហការរួម**របស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធនានា។ ភាគីនីមួយៗត្រូវអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនឱ្យបានច្បាស់លាស់ ស្របតាមសមត្ថកិច្ច និងធនធានដែលមាន។ ជាពិសេស ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវពង្រឹងភាពជាម្ចាស់ក្នុងការរៀបចំ អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារគណនេយ្យភាពសង្គម ខណៈដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលគួរផ្តោតលើការគាំទ្របច្ចេកទេស ការចែករំលែកបទពិសោធន៍ និងការច្នៃប្រឌិត ជាជាងការអនុវត្តជំនួសស្ថាប័នរដ្ឋ។

ជារួម **ISAF-III ផ្តោតលើការពង្រឹង និងធ្វើស្ថាប័នភាវូបនីយកម្មគណនេយ្យភាពសង្គមនៅក្នុងប្រព័ន្ធអភិបាលកិច្ច និងការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា។** ជោគជ័យនៃ ISAF-III នឹងមិនត្រូវវាស់ត្រឹមចំនួនរដ្ឋបាលដែលបានអនុវត្ត ឬចំនួនសកម្មភាពដែលបានអនុវត្តនោះទេ ប៉ុន្តែត្រូវវាស់តាមកម្រិតដែលគណនេយ្យភាពសង្គមត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធ និងនីតិវិធីការងាររបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ កម្រិតដែលរដ្ឋបាលមូលដ្ឋានមានភាពម្ចាស់ការ និងមានធនធានសម្រាប់អនុវត្ត កម្រិតដែលប្រជាពលរដ្ឋមានឱកាស និងទំនុកចិត្តក្នុងការចូលរួម និងកម្រិតដែលសម្លេង និងតម្រូវការរបស់ប្រជាពលរដ្ឋត្រូវបានបម្លែងទៅជាការសម្រេចចិត្ត និងសកម្មភាពជាក់ស្តែងសម្រាប់កែលម្អសេវាសាធារណៈ។

**គ.ជ.អ.ប. មានជំនឿថា តាមរយៈការអនុវត្ត ISAF-III ប្រកបដោយការដឹកនាំច្បាស់លាស់ កិច្ចសហការរួម ភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ការចូលរួមប្រកបដោយអត្ថន័យរបស់ប្រជាពលរដ្ឋ និងការគាំទ្រសមស្របពីដៃគូពាក់ព័ន្ធ គណនេយ្យភាពសង្គមនឹងត្រូវបានពង្រឹង ពង្រីក និងធ្វើឱ្យមាននិរន្តរភាពនៅទូទាំងប្រទេស។ លទ្ធផលនេះនឹងរួមចំណែកពង្រឹងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ លើកកម្ពស់គុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវាសាធារណៈ និងធានាថា ប្រជាពលរដ្ឋទទួលបានផលប្រយោជន៍ពីការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដែលឆ្លើយតបទៅនឹងតម្រូវការរបស់ខ្លួនប្រកបដោយបរិយាបន្ន និងសមធម៌សង្គម។**

សេចក្តីព្រាង